អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
អគ្គនាយកដ្ឋានស្រាវជ្រាវ
នាយកដ្ឋានស្រាវជ្រាវថវិកា

# ព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច

## មាតិកា៖

- បំណុលកម្ពុជា អាចនឹងកើនដល់ ៣៥% នៃ GDP នៅឆ្នាំ២០២២
- ហេតុអ្វីការបញ្ចុះតម្លៃពន្ធលើប្រេងសាំងមិនទាន់ជាជម្រើសល្អសម្រាប់កម្ពុជា ?
- ក្រុមហ៊ុនសិង្ហបុរី បង្កើតមជ្ឈមណ្ឌលកសិកម្មនៅស្រុកឳរ៉ាល់ ប្រមូលផ្តុំការវិនិយោគកសិកម្ម រ៉ែថ្ម កែច្នៃចំណីអាហារ និងផលិតថាមពលព្រះអាទិត្យ
- ក្រុមហ៊ុនជាតិ និងអន្តរជាតិធំៗចំនួន៥ ពួតដៃគ្នាជំរុញការវិនិយោគអចលនទ្រព្យរវាងកម្ពុជា និងអឺរ៉ុប
- ការប្រើប្រាស់បច្ចេកទេសកសិកម្មថ្មីរបស់ប្រទេសកម្ពុជា បាននឹងកំពុងជួយបង្កើតការងារនៅតាមទីជនបទ
- វិស័យណាខ្លះ ដែលជំរុញសេដ្ឋកិច្ចកម្ពុជាឱ្យសម្រេចបាន ៥,៦% នៅឆ្នាំ២០២២
- កម្ពុជាជួយដល់សហគ្រាសធុនតូច និងមធ្យម និងវិស័យកសិកម្ម
- រដ្ឋាភិបាលវៀតណាមនឹងកាត់បន្ថយពន្ធលើប្រេង និងកម្រៃសេវា ដើម្បីទប់ការឡើងថ្លៃប្រេង
- ក្រោយដកខ្លួនពីមីយ៉ាន់ម៉ា ក្រុមហ៊ុនភេសជ្ជៈជប៉ុន Kirin ងាកទៅរកការផលិតនៅអាមេរិក និងអូស្ត្រាលី
- ទូតម៉ាឡេស៊ី ៖ ច្បាប់វិនិយោគថ្មីរបស់កម្ពុជា បង្ហាញកាន់តែច្បាស់ ពីការលើកទឹកចិត្តដល់វិនិយោគិន
- JPMorgan រំពឹងថា ធនាគារសហព័ន្ធអាមេរិក នឹងបន្តតម្លើងការប្រាក់ ដើម្បីដោះស្រាយបញ្ហាអតិផរណា
- សេដ្ឋកិច្ចតំបន់ចាយប្រាក់អឺរ៉ូ បានងើបឡើង ទោះបីជាថ្លៃហក់ឡើងខ្ពស់
- អឺរ៉ុបព្រមាន រុស្ស៊ីអាចនឹងបាត់បង់ការទទួលបានទីផ្សារហិរញ្ញវត្ថុ និងទំនិញសំខាន់ បើឈ្លានពានអ៊ុយក្រែន


ពិនិត្យ និងកែសម្រួលដោយ

- សួន ពុធថាវី — អគ្គនាយិកា នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- គឹម សុចិត្រា — អគ្គនាយករង នៃអគ្គនាយកដ្ឋានស្រាវជ្រាវ
- ណុប ចាន់ធី — ប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា
- ម៉ែន ខែមរៈ — អនុប្រធាននាយកដ្ឋានស្រាវជ្រាវថវិកា



រៀបរៀងដោយនាយកដ្ឋានស្រាវជ្រាវថវិកា　　សប្តាហ៍ទី១ ខែមីនា ឆ្នាំ២០២២　　លេខ ៖ ១០៨

## ព័ត៌មាន និងទិន្នន័យអំពីប្រទេសកម្ពុជា

### បំណុលកម្ពុជា អាចនឹងកើនដល់ ៣៥% នៃ GDP នៅឆ្នាំ២០២២



*ដោយ ខេមបូណ្ឌមីស*

រដ្ឋលេខាធិការប្រចាំការក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានអះអាងថា បើទោះជា ក្នុងអំឡុងពេលជំងឺរាតត្បាតកូវីដ-១៩ ការចំណាយថវិការដ្ឋរីកកាន់តែធំ និងចំណូលប្រឈមនឹងការថមថយ ក៏ប៉ុន្តែរាជរដ្ឋាភិបាលកម្ពុជា នៅតែអាចគ្រប់គ្រងស្ថានការណ៍ បានយ៉ាងល្អនៅក្នុងរយៈពេល២ឆ្នាំកន្លងមកនេះ ហើយក្នុងនោះ កម្រិតនៃការខ្ចីបំណុលរបស់កម្ពុជាពីដៃគូក្រៅប្រទេស បានធ្វើឡើងក្នុងលក្ខណៈធម្មតា ពោលគឺ មិនមានការខ្ចីច្រើនខ្លាំងនោះទេ។

នៅក្នុងអំឡុងការរីករាលដាលនៃវិបត្តិជំងឺកូវីដ-១៩នេះ ការខ្ចីបំណុលរបស់ប្រទេសក្រីក្រ ក៏ដូចជាប្រទេសកំពុងអភិវឌ្ឍជាច្រើន មានការកើនឡើងកាន់តែច្រើន ដើម្បីយកមកចំណាយទ្រទ្រង់សេដ្ឋកិច្ចសង្គម ដែលនេះបានបានបង្កើតជាហានិភ័យមួយសម្រាប់ប្រទេសទាំងនោះ។ ដោយឡែក សម្រាប់កម្ពុជា កម្រិតបំណុលបច្ចុប្បន្ន គឺស្ថិតក្រោមកម្រិតហានិភ័យនៅឡើយ។ ប៉ុន្តែបើតាមការគ្រោងទុកនៅឆ្នាំ២០២២នេះ បំណុលសាធារណៈកម្ពុជារំពឹងថា នឹងកើនឡើងដល់ប្រមាណ ៣៥% នៃទំហំផលិតផលក្នុងស្រុកសរុប(ផ.ស.ស) ក៏ប៉ុន្តែសម្រាប់បំណុលគិតតម្លៃពិតបច្ចុប្បន្ន (Net Present Value) ទើបតែមានជាង ២១% នៃផ.ស.សប៉ុណ្ណោះ។ គួរឱ្យកត់សម្គាល់ថា ការខ្ចីបំណុលរបស់កម្ពុជានៅមានកម្រិតទាប ព្រោះកម្ពុជាមានប្រាក់សន្សំ ដែលអាចជួយបំពេញបង្គ្រប់សម្រាប់ការចំណាយ។ តួយ៉ាង នៅឆ្នាំ២០២០ កម្ពុជាបានដកសាច់ប្រាក់សន្សំជាង ២៤០លានដុល្លារយកមកប្រើប្រាស់ ហើយនៅឆ្នាំ២០២១ បានដកមកចាយជិត ១ ៤០០លានដុល្លារអាមេរិក និងបានគ្រោងប្រមាណ ៥០០លានដុល្លារអាមេរិក សម្រាប់ឆ្នាំ២០២២នេះ។

ឆ្នាំ២០២២ ហាក់បីដូចជាឆ្នាំមួយដ៏លំបាកសម្រាប់កម្ពុជា ដោយសារ រាជរដ្ឋាភិបាល ត្រូវការចំណាយកាន់តែច្រើនជាងមុន។ ក្រៅពីការគ្រោងចំណាយលើការស្តារ និងជំរុញសេដ្ឋកិច្ចពីវិបត្តិកូវីដ-១៩ ដែលមានទំហំប្រហែលជាង ១ប៊ីលានដុល្លារនៅឆ្នាំ២០២២នេះ រាជរដ្ឋាភិបាលក៏នៅមានការចំណាយផ្សេងទៀត ពិសេស ការចំណាយលើការរៀបចំធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំអាស៊ាន (គ្រោងចំណាយពី៤០ ទៅ៥០លានដុល្លារ) និងការចំណាយលើការរៀបចំការបោះឆ្នោត (ប្រមាណ ៧០លានដុល្លារអាមេរិក) ផងដែរ។ គួរបញ្ជាក់ថា កត្តាដែលទាញឱ្យការចំណាយរបស់រាជរដ្ឋាភិបាលកាន់តែរីកធំ គឺចំណាយលើការផ្តល់អន្តរាគមន៍លើវិស័យសុខភាពសាធារណៈ និងសេដ្ឋកិច្ចសង្គម។

ដាក់ស្តែង គិតត្រឹមដំណាច់ឆ្នាំ២០២១ កម្ពុជាមានសន្និធិបំណុលសាធារណៈក្រៅប្រទេសសរុបជាង ៩៥០០លានដុល្លារអាមេរិក យោងតាមរបាយការណ៍របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។ ក្នុងនោះ បំណុលប្រទេសចិនជាង ៤០% បំណុលពហុភាគីមាន ៣០% បំណុលជំពាក់ប្រទេសជប៉ុន មាន ៩% និងកូរ៉េខាងត្បូងមាន ៥% បំណុលទ្វេភាគីផ្សេងទៀតមាន ៦% និងបំណុលមរតក ដែលកំពុងចរចាដោះស្រាយមាន៧%។ ទន្ទឹមនេះ រាជរដ្ឋាភិបាលកម្ពុជាក៏មានគោលដៅ ងាកមករកការខ្ចីបំណុលក្នុងស្រុកផងដែរ ដោយនៅឆ្នាំ២០២២នេះ កម្ពុជាគ្រោងនឹងធ្វើការបោះផ្សាយលក់មូលបត្របំណុលរដ្ឋជាលើកដំបូង ក្នុងតម្លៃប្រមាណ៣០០លានដុល្លារអាមេរិក៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណូមីស ចេញផ្សាយថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២២។*

## ហេតុអ្វីការបញ្ចុះតម្លៃពន្ធលើប្រេងសាំងមិនទាន់ជាជម្រើសល្អសម្រាប់កម្ពុជា?




*ដោយ ខេមបូណូមីស*

បច្ចុប្បន្ន តម្លៃប្រេងឥន្ធនៈលក់រាយតាមស្ថានីយ៍នីមួយៗនៅកម្ពុជា បានបន្តកើនឡើងទាំងសាំងស៊ុបពែរ សាំងធម្មតា និងប្រេងម៉ាសូត។ ជុំវិញបញ្ហានេះ ប្រជាពលរដ្ឋកម្ពុជា ពិសេសអ្នកប្រកបរបររត់តាក់ស៊ី បានស្នើ រាជរដ្ឋាភិបាលកម្ពុជា ជួយរកដំណោះស្រាយ។

រដ្ឋលេខាធិការប្រចាំការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានគូសបញ្ជាក់ថា ការឡើងថ្លៃប្រេងឥន្ធនៈកំពុងប៉ះពាល់ដល់ជីវភាពប្រជាពលរដ្ឋ ពិសេសអ្នកប្រកបរបររត់ម៉ូតូឌុប រ៉ឺម៉កកង់បី និងតាក់ស៊ីជាដើម។ ក៏ប៉ុន្តែ បញ្ហានេះ មិនមែនកើតមាននៅតែកម្ពុជាទេ ពោលគឺ នៅទូទាំងពិភពលោក។

ទន្ទឹមនេះ ក៏មានការចោតជាសំណួរសួរថា តើរាជរដ្ឋាភិបាលកម្ពុជា អាចជួយបន្ធូរបន្ថយពន្ធលើប្រេងសាំងដើម្បីឱ្យតម្លៃថយចុះទាបជាងមុនដែរឬទេ? ឆ្លើយតបនឹងសំណួរនេះ រដ្ឋលេខាធិការប្រចាំការនៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ បានពន្យល់យ៉ាងដូច្នេះថា កាលណាបញ្ចុះពន្ធ មានន័យថា ប្រាក់ចំណូលរបស់ជាតិនឹងត្រូវធ្លាក់ចុះ ដូច្នេះ រាជរដ្ឋាភិបាលមិនទាន់អាចបញ្ចុះតម្លៃពន្ធលើប្រេងឥន្ធនៈបាននោះទេ ព្រោះវាប៉ះពាល់ដល់ចំណូល និងថវិកាជាតិដែលត្រូវប្រើប្រាស់សម្រាប់ទ្រទ្រង់សេដ្ឋកិច្ច ជាពិសេស ការជួយទៅដល់ពលរដ្ឋក្រីក្រដែលងាយរងគ្រោះដោយសារតែវិបត្តិកូវីដ-១៩។ បន្ថែមពីនេះ រាជរដ្ឋាភិបាលក៏មិនបានបណ្តោយឱ្យតម្លៃប្រេងឥន្ធនៈ ឡើងតាមចិត្តនៅលើទីផ្សារនោះដែរ ដោយ កន្លងមក រាជរដ្ឋាភិបាលបានកំណត់ទំហំពន្ធមួយច្បាស់លាស់ជាមូលដ្ឋាន បើទោះជាតម្លៃប្រេងឡើង ឬចុះខ្លាំង ប៉ុន្តែតម្លៃប្រេងលក់រាយលើទីផ្សារមិនឡើងថ្លៃខ្ពស់ខ្លាំងនោះទេ។ គួរបញ្ជាក់ថា ក្នុងមួយខែៗ ថវិកាចំណាយរដ្ឋប្រមាណជា ៣០លានដុល្លារ ត្រូវបានប្រើប្រាស់ដើម្បីឧបត្ថម្ភដល់អ្នកក្រីក្រ និងងាយរងគ្រោះ ដោយសារវិបត្តិកូវីដ-១៩ ដូច្នេះ ការកាត់បន្ថយពន្ធលើប្រេងសាំងនៅមិនទាន់ជាជម្រើសល្អនោះឡើយ។ ទន្ទឹមនេះដែរ ក្រសួងពាណិជ្ជកម្ម ក៏តាមដានការលក់រាយរៀងរាល់ខែ ដើម្បីកំណត់ថ្លៃប្រេងឥន្ធនៈលក់រាយនៅតាមស្ថានីយនីមួយៗ សម្រាប់ប្រេងសាំងធម្មតា និងម៉ាសូត ដើម្បីកុំឱ្យមានកេងបន្លំផ្សេងៗផងដែរ។

ជាមួយគ្នានេះ មន្ត្រីតំណាងអគ្គនាយកដ្ឋាគយ និងរដ្ឋាករកម្ពុជា ក៏បានគូសបញ្ជាក់ថា តម្លៃទំនិញនាំចូលត្រូវបានគិតគូរតាមតម្លៃជាក់ស្តែងលើទីផ្សារ ក៏ប៉ុន្តែសម្រាប់ការនាំចូលប្រេងសាំង រាជរដ្ឋាភិបាលបានគិតគូរ តាមតម្លៃមួយថេរ។ ទោះបីជាទំនិញនៅលើទីផ្សារអន្តរជាតិឡើងថ្លៃ ក៏ប៉ុន្តែ រាជរដ្ឋាភិបាលបានគិតគូរមិនដំឡើងទៅតាមតម្លៃទីផ្សារពិភពលោកនោះទេ ពោល គិតពន្ធតាមតម្លៃមួយថេរ ដែលបានកំណត់។ ជាក់ស្តែង តម្លៃប្រេងលើទីផ្សារពិភពលោកបច្ចុប្បន្នក្នុងមួយធុងបារ៉ែល បានឡើងដល់ជាង ៩០ដុល្លារទៅហើយ ដោយសារតែបញ្ហាភាពតានតឹងភូមិសាស្ត្រនយោបាយ ដែលបានបង្កជាក្តីបារម្ភថា អាចនឹងប៉ះពាល់ដល់ខ្សែចង្វាក់ផ្គត់ផ្គង់ប្រេងឆៅ។ អ្នកជំនាញមួយចំនួនធ្លាប់បានលើកឡើងថា ប្រសិនបើស្ថានការវិវត្តកាន់តែអាក្រក់ទៅៗ នោះតម្លៃប្រេងឥន្ធនៈលើទីផ្សារពិភពលោកអាចបន្តកើនឡើងថែមទៀត រហូតដល់ទៅជាង១០០ដុល្លារ ក្នុងមួយធុងបារ៉ែល។ តម្លៃប្រេងពិភពលោកឡើងថ្លៃ ក៏កំពុងបង្កឱ្យកើតមានអតិផរណាកើនឡើងនៅជុំវិញពិភពលោកផងដែរ៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណ្ឌមីស ចេញផ្សាយថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២២។*

## វិស័យកាត់ដេរនិងវាយនភណ្ឌឆ្នាំ២០២២បន្តកើនឡើង



*ដោយ ខេមបូណ្ឌមីស*

អគ្គលេខាធិការរងសមាគមរោងចក្រកាត់ដេរនៅកម្ពុជា បានគូសបញ្ជាក់ថា ត្បិតកម្ពុជា បានទទួលរងឥទ្ធិពលអវិជ្ជមានពីវិបត្តិកូវីដ-១៩ អស់រយៈពេលជាង ២ឆ្នាំ តែវិស័យកាត់ដេរ និងវាយនភ័ណ្ឌ នៅតែអាចរក្សាបាននូវស្ថិរភាព ហើយសមាគមបាមរំពឹងថា នៅឆ្នាំ២០២២នេះ ការនាំចេញផលិតផលកាត់ដេរ នឹងបន្តមានកំណើនក្នុងកម្រិតសមរម្យមួយ។

ប្រធានសមាគមស្បែកជើងកម្ពុជា ក៏បានបង្ហាញពីភាពវិជ្ជមាននៃវិស័យកាត់ដេរ និងវាយនភ័ណ្ឌរបស់កម្ពុជាដែរថា នឹងនៅតែបន្តមានកំណើនសម្រាប់ឆ្នាំ២០២២នេះ ដោយសារមានឱកាសទីផ្សារអាមេរិក អឺរ៉ុប និងអាស៊ី ជាពិសេស អាចនាំចេញទៅចិន និងកូរ៉េ ដោយសារមានកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី។ នៅឆ្នាំ២០២១ ការនាំចេញស្បែកជើងបានកើនឡើង ២០% ក្នុងនោះ បាននាំចេញទៅកាន់ទីផ្សារអឺរ៉ុប អាមេរិក ប្រទេសកាណាដា ប្រទេសជប៉ុន និងប្រទេសកូរ៉េ។ ការនាំចេញផលិតផលកាត់ដេរ បានកើនឡើង តែវិបត្តិកូវីដ-១៩បានប៉ះពាល់ដល់វិស័យនេះខ្លះៗដែរ ជាពិសេសលើមធ្យោបាយដឹកជញ្ជូន ដោយរហូតមកទល់ពេលនេះ ហាក់នៅមិនទាន់អាចដោះស្រាយបាននៅឡើយ ដែលធ្វើឱ្យការដឹកជញ្ជូនទំនិញមានភាពយឺតយ៉ាវបន្តិច តែមិនប៉ះពាល់ខ្លាំងដល់ការដឹកជញ្ជូនទំនិញទៅកាន់គោលដៅទីផ្សារនោះទេ។

យោងតាមរបាយការណ៍របស់អគ្គនាយកដ្ឋានគយ និងរដ្ឋាករកម្ពុជា នៅឆ្នាំ២០២១ កម្ពុជា បានទទួលចំណូលជាង១១ប៊ីលានដុល្លារ ពីការនាំចេញផលិតផលកាត់ដេរ ពោល កើនឡើងប្រមាណ១៥% បើប្រៀបធៀបនឹងឆ្នាំ២០២០។ ដោយឡែកចំណូលពីការនាំចេញផលិតផលមិនមែនកាត់ដេរវិញមានជាង ៤ប៊ីលានដុល្លារ រួមមានគ្រឿងបន្លាស់រថយន្ត ផលិតផលឧស្សាហកម្ម គ្រឿងបំណែកអេឡិចត្រូនិក និងកង់ ជាដើម។ បើទោះបី កម្ពុជានៅតែបន្តជួបបញ្ហាជំងឺរាតត្បាតកូវីដ-១៩ តែសកម្មភាព

នៃការនាំចេញផលិតផលកាត់ដេរ ទៅកាន់ទីផ្សារអន្តរ-ជាតិនៅតែបន្ត៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូឌាមីស ចេញផ្សាយថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២២។*

## ក្រុមហ៊ុនសឹង្ហបុរី បង្កើតមជ្ឈមណ្ឌលកសិកម្មនៅស្រុកឱរ៉ាល់ ប្រមូលផ្ដុំការវិនិយោគកសិកម្ម រ៉ែថ្ម កែច្នៃចំណីអាហារ និងផលិតថាមពលព្រះអាទិត្យ




ក្រុមហ៊ុន អេច អិល អេច អាហ្គ្រីខលឈ័រ (ខេមបូឌា) លីមីតធីត និង ក្រុមហ៊ុន ហុង ឡៃហួត គ្រុប លីមីតធីត ដែលជាក្រុមហ៊ុនសឹង្ហបុរី បានបង្កើតមជ្ឈមណ្ឌលកសិកម្មលើផ្ទៃដីប្រមាណ ១ម៉ឺនហិចតា ស្ថិតនៅស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺ ដើម្បីប្រមូលផ្ដុំការវិនិយោគចំរុះលើវិស័យកសិ-កម្ម មានដូចជា ការកែច្នៃចំណីអាហារ ចិញ្ចឹមសត្វ ទីកន្លែងពាណិជ្ជកម្ម និងចំការថាមពលព្រះអាទិត្យជាដើម។ ក្រុមហ៊ុនទាំងនេះ បានវិនិយោគលើការដាំពោត និងដំឡូងមី និងកែច្នៃជាម្សៅមីសម្រាប់នាំចេញទៅក្រៅប្រទេសលើទីតាំងខាងលើតាំងពីឆ្នាំ២០០៨មកម្ល៉េះ។ ដើម្បីពង្រីកសក្ដានុពលនៃការវិនិយោគលើដីសម្បទានសេដ្ឋកិច្ចនេះឱ្យកាន់តែខ្លាំងក្លាថែមទៀត ទើបក្រុមហ៊ុនសម្រេចបង្កើតទីតាំងនោះទៅជាមជ្ឈមណ្ឌលកសិកម្មកម្ពុជា-សិង្ហបុរី (CSAH) ដើម្បីកៀរគរអ្នកវិនិយោគផ្នែកកសិកម្មឱ្យចូលរួមវិនិយោគ និងកែប្រែតំបន់នោះ ទៅជាកន្លែងអភិវឌ្ឍន៍ផ្នែកកសិកម្មចម្រុះ និងទំនើបមួយ។

មជ្ឈមណ្ឌលកសិកម្មកម្ពុជា-សិង្ហបុរី គឺជាគម្រោងវិនិ-យោគដ៏ធំ និងជាគំនិតវិនិយោគបែបថ្មីមួយនៅកម្ពុជា។ មជ្ឈមណ្ឌលនេះ បានបែងចែកជា១៦តំបន់ ដែលអនុ-ញ្ញាតឱ្យអ្នកវិនិយោគអាចជ្រើសរើសការវិនិយោគតាមបំណងប្រាថ្នារបស់ខ្លួន។ តំបន់ទាំង១៦ ដែលត្រូវបានបង្កើតឡើងនៅក្នុងមជ្ឈមណ្ឌលកសិកម្មកម្ពុជា-សិង្ហបុរីនេះ រួមមាន៖ តំបន់ពាណិជ្ជកម្ម, តំបន់ដំណាំកសិកម្ម, តំបន់កសិកម្មចិញ្ចឹមសត្វ, តំបន់ឧស្សាហកម្មធុនស្រាល, តំបន់ឧស្សាហកម្មកែច្នៃអាហារ និងមជ្ឈមណ្ឌលដឹកជញ្ជូន, តំបន់កសិកម្មចិញ្ចឹមត្រី សត្វ និងថាមពលដើរដោយពន្លឺព្រះអាទិត្យ, តំបន់ថាមពលដើរដោយពន្លឺព្រះអាទិត្យ និងកសិកម្មចិញ្ចឹមសត្វ, ដីកម្មសិទ្ធិឯកជន, តំបន់ស្នាក់នៅ និងលំនៅដ្ឋានសាធារណៈ, តំបន់ជីកយករ៉ែថ្ម, តំបន់លក់សម្ភារៈសំណង់, រោងចក្រផ្គត់ផ្គង់ទឹក និងស្តុកទឹក, អាងស្តុកទឹកសម្រាប់ប្រព័ន្ធធារាសាស្រ្ត, កសិកម្មលំអរត្រី កង្កែប និងបង្កង, គម្រោងអភិវឌ្ឍចម្រុះ និងតំបន់សម្រាប់អាជីវកម្មលើរូបបដិមា។

ក្រុមហ៊ុន អេច អិល អេច អាហ្គ្រីខលឈ័រ (ខេមបូឌា) លីមីតធីត ដែលបានវិនិយោគនៅទីតាំងដីដែលជាសម្ប-ទានសេដ្ឋកិច្ចរបស់រាជរដ្ឋាភិបាលក្នុងស្រុកឱរ៉ាល់ ខេត្តកំពង់ស្ពឺនេះ តាំងពីឆ្នាំ២០០៨មក បានដាំដំឡូងមី និងបង្កើតជារោងចក្រសម្រាប់កែច្នៃដំឡូងមីជាម្សៅនាំចេញទៅកាន់ទីផ្សារក្រៅប្រទេស។ ការវិនិយោគនៅទីតាំងខាងលើនេះ គឺមានអំណោយផលខ្ពស់សម្រាប់ការដឹកជញ្ជូនផលិតផលដែលផលិតបានទៅកាន់ទីផ្សារ ដោយសារតែទីតាំងនៅជិតនឹងផ្លូវជាតិលេខ ៣, ៤, ៤១, ៤៤ និង៥១។ ការបង្កើតមជ្ឈមណ្ឌលកសិកម្មកម្ពុជា-សឹង្ហបុរី មិនត្រឹមតែរួមចំណែកធ្វើឱ្យប្រសើរឡើងនូវសេដ្ឋកិច្ចជាតិប៉ុណ្ណោះទេ តែក៏នឹងរួមចំណែកលើកកម្ពស់ជីវភាព

របស់ប្រជាពលរដ្ឋឱ្យកាន់តែប្រសើរផងដែរ ខណៈបច្ចុប្បន្នមានកម្មករសរុបជាង ៤០០នាក់ កំពុងបម្រើការងារនៅតំបន់អភិវឌ្ឍន៍វិស័យកសិកម្មដ៏ធំមួយនេះ។

តំណាងមកក្រុមហ៊ុននេះ បានអះអាងថា បន្ទាប់ពីក្រុមហ៊ុនបានប្រកាសដាក់ចេញនូវគម្រោងនេះ គឺមានការចាប់អារម្មណ៍ជាច្រើនពីអ្នកវិនិយោគទាំងក្នុង និងក្រៅប្រទេស៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ freshnews ចេញផ្សាយថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២២។*

## ក្រុមហ៊ុនជាតិ និងអន្តរជាតិធំៗចំនួន៥ ពួតដៃគ្នាជំរុញការវិនិយោគអចលនទ្រព្យរវាងកម្ពុជា និងអឺរ៉ុប




*ដោយ ខេមបុណ្ណមីស*

កម្ពុជាមានឱកាសកាន់តែប្រសើរ ក្នុងការទាក់ទាញវិនិយោគិនពីប្រទេសសមាជិកសហភាពអឺរ៉ុប មកបណ្តាក់ទុន។ ក្នុងនោះ មានក្រុមហ៊ុនអចលនទ្រព្យជាតិ និងអន្តរជាតិធំៗចំនួន៥ បានសម្រេចចុះអនុស្សារណៈយោគយល់គ្នា ដើម្បីបង្កើតឱកាសវិនិយោគថ្មី។ ក្រុមហ៊ុនធំៗទាំង៥ ដែលបានចាប់ដៃគ្នាលើការវិនិយោគអចលនទ្រព្យនោះ រួមមាន ក្រុមហ៊ុន Zillennium Co., Ltd (Z1 Group), ក្រុមហ៊ុន Z1 Financial, ក្រុមហ៊ុន Century 21 Fortuna Investment, ក្រុមហ៊ុន Mercan Group និងក្រុមហ៊ុន Mercadia Cambodia។

ប្រធានក្រុមប្រឹក្សាភិបាល ក្រុមហ៊ុន Zillennium Co., Ltd (Z1 Group) បានចាត់ទុកកិច្ចសហការនេះ ជាការផ្តុំកម្លាំងរួមគ្នាដ៏សំខាន់ជំរុញឱ្យមានការវិនិយោគទៅវិញទៅមក ដែលស្មារតីរួមគ្នានេះ នឹងជួយពន្លឿនការវិនិយោគនៅកម្ពុជា។ ទន្ទឹមនេះដែរ ស្ថាបនិកក្រុមហ៊ុន Mercan Group បានលើកឡើងថា អ្នកវិនិយោគនៅកម្ពុជា អាចចូលរួមវិនិយោគជាមួយគម្រោងរបស់លោក តាមរយៈក្រុមហ៊ុន Century 21 Fortuna Investment ដែលជាដៃគូសហការយុទ្ធសាស្ត្រ ដើម្បីទទួលបានការវិនិយោគប្រកបដោយសុវត្ថិភាព និងផលចំណេញល្អ។ ការចុះហត្ថលេខាលើអនុស្សារណៈយោគយល់គ្នាពេលនេះ នឹងក្លាយជាការត្រួសត្រាយផ្លូវដ៏សំខាន់រវាងក្រុមហ៊ុនទាំងប្រាំ ក្នុងការសហការដែលនាំនូវឱកាសវិនិយោគថ្មីៗសម្រាប់ប្រជាជនកម្ពុជាដែលមានលទ្ធភាពទិញអចលនទ្រព្យនៅប្រទេសព័រទុយហ្គាល់។

ប្រទេសព័រទុយហ្គាល់ មិនត្រឹមតែមានសក្តានុពលសម្រាប់ការវិនិយោគប៉ុណ្ណោះទេ តែក៏មានអំណោយផលល្អសម្រាប់ការរស់នៅផងដែរ ដោយសារប្រទេសនេះមានសុវត្ថិភាពខ្ពស់ ប្រព័ន្ធសុខាភិបាលទំនើប ថែមទាំងជាប្រទេស មានការចាយវាយសមរម្យបំផុតក្នុងតំបន់អឺរ៉ុប ដែលទំនិញ និងសេវាកម្មជាច្រើនគឺមានតម្លៃប្រហាក់ប្រហែលនឹងប្រទេសកម្ពុជា។ ការទិញអចលនទ្រព្យនៅប្រទេសព័រទុយហ្គាល់ គ្រាន់តែតម្រូវឱ្យមានប្រាក់កក់ ៣០% ប៉ុណ្ណោះ និងអាចទទួលបានទំហំកម្ចី ៧០% នៃតម្លៃទ្រព្យ ជាមួយអត្រាការប្រាក់ត្រឹម ១,២% ក្នុងមួយឆ្នាំប៉ុណ្ណោះ។

គួរបញ្ជាក់ថា កិច្ចសហនាពេលនេះ ក៏នឹងបង្កលក្ខណៈងាយស្រួលដល់វិនិយោគិននៅកម្ពុជា ក្នុងការរកដៃគូសហការជាមួយអ្នកវិនិយោគបរទេស ដើម្បីមកបណ្តាក់ទុនវិនិយោគលើវិស័យសក្តានុពលផ្សេងៗនៅកម្ពុជា។ បើយោងតាមទិន្នន័យធនាគារពិភពលោកបានបង្ហាញថា លំហូរវិនិយោគផ្ទាល់ពីបរទេស (FDI) ដែលបានហូរទៅ

ក្នុងវិស័យអចលនទ្រព្យ និងសំណង់នៅកម្ពុជាក្នុងឆ្នាំ ២០១៩ និងឆ្នាំ២០២០ មានចំណែកដល់ទៅ ១ភាគ៣ នៃផ.ស.ស ។ FDI នៅកម្ពុជា សម្រេចបានទឹកប្រាក់ ជាង ៣,៤ប៊ីលានដុល្លារ ក្នុងឆ្នាំ ២០១៩ និង ៣,៦ប៊ីលានដុល្លារ ក្នុងឆ្នាំ២០២០៕ *ដោយ ម៉ែន ខែមរៈ*
*ប្រភព៖ខេមបូឌាមីស ចេញផ្សាយថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២២។*

## វិស័យណាខ្លះ ដែលជំរុញសេដ្ឋកិច្ចកម្ពុជាឱ្យសម្រេចបាន ៥,៦% នៅឆ្នាំ ២០២២




*ដោយ Kampucheathmey*

នៅឆ្នាំ២០២២ កំណើនសេដ្ឋកិច្ចកម្ពុជា រំពឹងថា សម្រេចបានក្នុងអត្រា ៥,៦%។ ការហក់ឡើងវិញនៃកំណើនសេដ្ឋកិច្ចនេះ គាំទ្រដោយកត្តាសំខាន់ៗពីរ ដូចជា ទី១) ការងើបឡើងវិញនៃតម្រូវការសកល និងការកើនឡើងថ្លៃកសិផលលើទីផ្សារអន្តរជាតិ ការជំរុញកំណើនវិស័យកាត់ដេរ វិស័យកម្មន្តសាលមិនមែនកាត់ដេរ កសិកម្ម (ដំណាំ)ជាដើម និងទី២) ការសម្រេចបាននៃអត្រាចាក់វ៉ាក់សាំងខ្ពស់ ដែលបង្កើតបានភាពស៊ាំក្នុងសហគមន៍ និងការបើកប្រទេសឡើងវិញជាផ្លូវការ ដែលបានជំរុញសកម្មភាពពាណិជ្ជកម្ម ធុរកិច្ចក្នុងស្រុកឱ្យត្រឡប់ទៅប្រក្រតីភាពវិញ។ ក៏ប៉ុន្តែ ការងើបឡើងវិញនៃជំងឺកូវីដ-១៩បំប្លែងថ្មីអូមីក្រុង ក្នុងប្រទេស បានបង្កជាបញ្ហាប្រឈមមួយ ដែលអាចនឹងរាំងស្ទះការងើបឡើងវិញ នូវសកម្មភាពពាណិជ្ជកម្ម-ធុរកិច្ច និងបង្កឱ្យមានការភ័យខ្លាចដល់សាធារណជន។

របាយការណ៍ជំនួយស្មារតីមួយរបស់ធនាគារពិភពលោក ដែលបានចេញផ្សាយនៅថ្ងៃទី៣១ ខែមករា ឆ្នាំ ២០២២ បានឱ្យដឹងថា សេដ្ឋកិច្ចប្រទេសកម្ពុជា ស្ថិតនៅក្នុងចំណោមសេដ្ឋកិច្ចតំបន់អាស៊ីបូព៌ា ដែលរងការខូចខាតយ៉ាងដំណំពីការរាតត្បាតនៃជំងឺកូវីដ-១៩ ប៉ុន្តែប្រទេសនេះ អាចស្តារសេដ្ឋកិច្ចឱ្យមានកំណើនទៀងទាត់ឡើងវិញបានតាមរយៈ ការបង្កើនផលិតភាពរបស់ក្រុមហ៊ុន និងពលករ ការពង្រីកពិពិធភាពក្នុងផ្នែកនាំចេញ និងចាត់វិធានការនានាឈានទៅជំរុញការវិនិយោគក្នុងស្រុក។ សូមបញ្ជាក់ថា ការប្រមូលចំណូលពន្ធ-អាកររបស់អគ្គ-នាយកដ្ឋានពន្ធដារនៅឆ្នាំ២០២១ សរុបបានចំនួន ជាង ២,៧ប៊ីលានដុល្លារ ស្មើនឹង១២៤,០២% កើនលើសផែនការក្នុងច្បាប់ហិរញ្ញវត្ថុឆ្នាំ២០២១ ចំនួន២៤,០២%៕ *ដោយ ម៉ែន ខែមរៈ*
*ប្រភព៖Kampucheathmeyចេញផ្សាយថ្ងៃទី១៨ខែកុម្ភៈឆ្នាំ២០២២។*

## ការប្រើប្រាស់បច្ចេកទេសកសិកម្មថ្មីរបស់ប្រទេសកម្ពុជាបាននឹងកំពុងជួយបង្កើតការងារនៅតាមទីជនបទ



*ប្រភព៖ ភ្នំពេញប៉ុស្តិ៍ ២០២២*

យោងតាមឯកឧត្តម វេង សាខុន រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលបានជួបពិភាក្សាការងារជាមួយនឹងក្រុមការងាររបស់មូលនិធិអន្តរជាតិសម្រាប់ការអភិវឌ្ឍន៍កសិកម្ម (IFAD) លើការអនុវត្តកម្មវិធីការប្រើប្រាស់បច្ចេកទេសកសិកម្មថ្មីដែលធន់នឹងការប្រែប្រួលអាកាសធាតុ (ASPIRE) បានលើកឡើងថា៖ កម្មវិធី

ASPIRE បានកំពុងដើរតួនាទីយ៉ាងសំខាន់ក្នុងការជួយបង្កើតការងារនៅតាមជនបទ ដោយបានបង្កើនប្រាក់ចំណូលក្នុងគ្រួសារ កាត់បន្ថយភាពក្រីក្រ និងធានាសន្តិសុខស្បៀង តាមរយៈការចិញ្ចឹមមាន់ ចិញ្ចឹមត្រី និងដាំបន្លែសុវត្ថិភាព ដោយប្រើប្រាស់បច្ចេកទេស និងធាតុចូលកសិកម្មថ្មីដែលធន់នឹងការប្រែប្រួលអាកាសធាតុ និងជាពិសេស មានភាពសមស្របតាមគន្លងប្រក្រតីភាពថ្មីក្នុងស្ថានភាពនៃវិបត្តិជំងឺឆ្លងកូវីដ-១៩។

បន្ថែមពីនេះ បច្ចុប្បន្នមានហាងលក់បន្លែសុវត្ថិភាព កំពុងរីកដុះដាលនៅតាមទីក្រុង ទីប្រជុំជន និងក្នុងសហគមន៍ដែលភាគច្រើនជាផលិតផលបន្លែ ផ្លែឈើ ត្រី សាច់ដែលផលិតចេញពីសហគមន៍ និងបណ្តុំផលិត ដែលស្ថិតនៅក្រោមជំនួយបច្ចេកទេសពីកម្មវិធី ASPIRE និងអនុវត្តផ្ទាល់ដោយអគ្គនាយកដ្ឋានកសិកម្ម និងស្ថាប័នពាក់ព័ន្ធគ្រប់លំដាប់ថ្នាក់។

ក្រៅពីនេះ សម្រាប់ការវិនិយោគរបស់កម្មវិធី ASPIRE កសិករគ្រាន់តែចំណាយដើមទុន ១ដុល្លារ កសិករអាចនឹងទទួលបានចំណូល៦៥ដុល្លារវិញ តាមរយៈការលក់ផលិតកម្មកសិកម្ម (បន្លែសុវត្ថិភាព) សត្វបក្សី (មាន់ ពង និងសាច់) និងត្រី ដោយបានអនុវត្តតាមកម្មវិធី ASPIRE ការអនុវត្តផលិត កម្មកសិកម្មតាមកិច្ចសន្យា ការប្រើប្រាស់ផ្ទះសំណាញ់ ប្រព័ន្ធដំណក់ទឹក ការប្រើថ្នាំដីកសិកម្ម និងធាតុចូលកសិកម្មផ្សេងៗតាមបច្ចេកទេសត្រឹមត្រូវ និងការរៀបចំទីផ្សារលក់ផលិតផលតាមសហគមន៍។

គម្រោងកម្មវិធី ASPIRE បានគ្រោងថវិកាជាង ១៥០ លានដុល្លារអាមេរិក ដែលបានចាប់ផ្តើមអនុវត្តពីឆ្នាំ ២០២២ រហូតដល់ឆ្នាំ ២០២៧។ ក្រុមការងារ និងដៃគូអភិវឌ្ឍន៍គម្រោងនេះបានសិក្សាពិនិត្យវាយតម្លៃលើលទ្ធផលសម្រេចបានឱ្យសមស្របទៅតាមតម្រូវការ និងស្ថានភាពសង្គមជាក់ស្តែង។

ជាក់ស្តែង ការប្រើប្រាស់បច្ចេកទេសថ្មីៗនៅមិនទាន់មានភាពសម្បូរបែបនៅទូទាំងកម្ពុជានៅឡើយទេ ព្រោះ ការប្រើប្រាស់បច្ចេកទេសទំនើបៗមួយចំនួន គឺមានតែអ្នកមានលទ្ធភាពប៉ុណ្ណោះ។ ដោយឡែក កសិករខ្នាតតូច ឬនៅទីជនបទ នៅតែអនុវត្តប្រព័ន្ធបែបទំនៀមទម្លាប់នៅឡើយ ដូចនេះទាមទារឱ្យមានការយកចិត្តទុកដាក់បន្ថែមទៀតពីសំណាក់ក្រសួងកសិកម្ម មន្ត្រីបច្ចេកទេស ក្នុងការចុះគាំពារកត្តាបច្ចេកទេសការដាំដុះ និងប្រើប្រាស់ដល់ប្រជាពលរដ្ឋ៕ *ដោយ សេន ចន្ទ*

*ប្រភព៖ [ភ្នំពេញប៉ុស្តិ៍ ចេញផ្សាយថ្ងៃទី២១ខែកុម្ភៈ ឆ្នាំ២០២២]*

## កម្ពុជាជួយដល់សហគ្រាសធុនតូច និងមធ្យម និងវិស័យកសិកម្ម



*ប្រភព៖ [ខ្មែរថាមស៍ ២០២២ , រូបភាព ស៊ីវ ចាន់ណា]*

យោងតាមឯកឧត្តម អូន ព័ន្ធមុនីរ័ត្ន ឧបនាយករដ្ឋមន្ត្រី និងជារដ្ឋមន្ត្រីសេដ្ឋកិច្ច និងហិរញ្ញវត្ថុបានលើកឡើងថា៖ រដ្ឋាភិបាលកម្ពុជាបានផ្តល់ប្រាក់កម្ចីដែលមានតម្លៃ ១០០ លានដុល្លារ ដើម្បីជួយដល់សហក្រាសធុនតូច និងមធ្យម និងវិស័យកសិកម្ម ក្នុងគោលបំណងស្តារសេដ្ឋកិច្ចកម្ពុជាឱ្យងើបឡើងវិញ។ ប្រាក់កម្ចីទាំងនេះនឹងត្រូវផ្តល់ឱ្យវិស័យឯកជន តាមរយៈ ធនាគារសហគ្រាសធនតូច និងមធ្យមរបស់រដ្ឋ និងធនាគារអភិវឌ្ឍន៍ជនបទ និងកសិកម្ម ហើយប្រាក់ម្ចីនេះនិងត្រូវប្រើប្រាស់ដើម្បីជំរុញ

វិស័យកសិកម្ម និងសហគ្រាសធុនតូច និងមធ្យម ដែលជាវិស័យអាទិភាពសំខាន់នៅក្នុងសេដ្ឋកិច្ចរបស់កម្ពុជា ព្រោះវិស័យទាំងពីរនេះ បានបង្កើតការងារ និងលើកកម្ពស់ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ព្រមទាំងចូលរួមចំណែកក្នុងការលើកកម្ពស់កំណើនសេដ្ឋកិច្ចជាតិ។ គួរបញ្ជាក់ថា ថវិកា១០០លានដុល្លារ នឹងត្រូវបែងចែកទៅឱ្យស្ថាប័នហិរញ្ញវត្ថុទាំងពីរស្មើៗគ្នា សម្រាប់យកទៅប្រើប្រាស់ក្នុងការអនុវត្តគាំទ្រដល់ឧស្សាហកម្មស្រូវអង្ករ ការចិញ្ចឹមសត្វ ផលិតកម្មដំណាំ និងគម្រោងហិរញ្ញប្បទានរួម៕ *ដោយ មុំ ចិន្តា*

*ប្រភព៖ ខ្មែរថាមស៍ ចេញផ្សាយថ្ងៃទី ២២ ខែកុម្ភៈ ឆ្នាំ២០២២*

## អាជ្ញាធរ ដាក់ដេញថ្លៃប្រមូលផល អនុផលព្រៃឈើនៅអាងស្តុកទឹកនៃគម្រោងវារីអគ្គិសនីស្ទឹងពោធិ៍សាត់១



*រូបភាព៖ រដ្ឋបាលខេត្តពោធិ៍សាត់(គម្រោងវារីអគ្គិសនីស្ទឹងពោធិ៍សាត់១)*

ក្រុមការងារចម្រុះដេញថ្លៃ នឹងធ្វើការដាក់ដេញថ្លៃជាសាធារណៈ នូវផលអនុផលព្រៃឈើ ដើម្បីសម្អាតអាងស្តុកទឹកនៃគម្រោងវារីអគ្គិសនីស្ទឹងពោធិ៍សាត់១ មានទីតាំងស្ថិតក្នុងស្រុកវាលវែង ខេត្តពោធិ៍សាត់ ដើម្បីប្រមូលបង់ថ្លៃសួយសារ និងបុព្វលាភចូលថវិកាជាតិ។ តម្លៃមូលដ្ឋាននៃការដេញថ្លៃនោះ គឺមានតម្លៃជាង៤៣០ ០០០ដុល្លារ។ ការដេញថ្លៃប្រមូលផល អនុផលព្រៃឈើប៉ាន់ស្មាន មានបរិមាណប៉ាន់ស្មានធនធានព្រៃឈើ មានដូចជា ឈើឈរចម្រុះប្រភេទសរុបចំនួន ៩ពាន់ម៉ែត្រគូប កូនឈើចម្រុះសរុបចំនួន ៦៥ ៤៩០ដើម និងអុសចម្រុះសរុបចំនួន ១៥៣ ១៧៥ស្ទែរ។

រូបវន្តបុគ្គល និងនីតិបុគ្គលអាចចូលរួមក្នុងការដេញថ្លៃ លើកលែងតែអ្នកធ្លាប់មានប្រវត្តិប្រព្រឹត្តបទល្មើសព្រៃឈើ និងអ្នកជាប់ជំពាក់បំណុលរដ្ឋ ហើយការចូលរួមដេញថ្លៃ ត្រូវមានការបំពេញសំណុំបែបបទ និងលក្ខខណ្ឌដូចមានចែងក្នុងសៀវភៅបន្ទុកដេញថ្លៃ៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូឌាមីស ចេញផ្សាយថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០២២។*

## រោងចក្រផ្គុំដំឡើងរថយន្ត អ៊ីស៊ូហ្ស៊ូ (ISUZU) នឹងលេចរូបរាងនៅស្រុកសំរោងទង



*ដោយ Kampucheathmey*

ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានសម្រេចចេញវិញ្ញាបនបត្រចុះបញ្ជីគម្រោងវិនិយោគ ដល់ក្រុមហ៊ុន K (CAMBODIA) CO., LTD លើគម្រោងបង្កើតរោងចក្រផ្គុំដំឡើងរថយន្ត អ៊ីស៊ូហ្ស៊ូ (ISUZU) ដែលមានទីតាំង ស្ថិតនៅភូមិសង្គ្រោះជាតិ ឃុំត្រពាំងគង ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ និងមានទុនវិនិយោគប្រមាណ ៧,៣លានដុល្លារអាមេរិក។ ក្រៅពីគម្រោងខាងលើ ក៏មានគម្រោងជាច្រើនទៀត ដែលមានទុនវិនិយោគ និងបង្កើតការងារច្រើនរួមមាន៖

១. គម្រោងបង្កើតរោងចក្រផ្គុំដំឡើងអំពូលភ្លើង គ្រឿងអេឡិចត្រូនិក និងគ្រឿងបន្លាស់អេឡិចត្រូនិកគ្រប់ប្រភេទរបស់ក្រុមហ៊ុន MEKO INTELLIGENT (CAMBODIA) CO., LTD ស្ថិតនៅភូមិវះពោះឃុំខ្វាវ ស្រុកសំរោង ខេត្ត

តាកែវ មានទុនវិនិយោគប្រមាណ ៣២លានដុល្លារអាមេរិក។

២. KHALANDALE CO., LTD: គម្រោងសាងសង់ផ្សារទំនើប មានទីតាំងស្ថិតនៅដីឡូត៍លេខ Mx04 (CBD6) បឹងកក់ ភូមិ១ សង្កាត់ស្រះចក ខណ្ឌដូនពេញ រាជធានីភ្នំពេញ និងមានទុនវិនិយោគចំនួន ១០លានដុល្លារអាមេរិក។

៣. B.E.C.I.S (CAMBODIA) CO., LTD: គម្រោងបង្កើតរោងចក្រផលិតចំហាយទឹក និងខ្យល់ក្តៅផ្គត់ផ្គង់ឱ្យរោងចក្រផលិតស្រាបៀរ និងភេសជ្ជៈ មានទីតាំងស្ថិតនៅភូមិរបោះអង្កាញ់ សង្កាត់ព្រៃកឯង ខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ និងទុនវិនិយោគប្រមាណ ៦,៧លានដុល្លារអាមេរិក។

៤. CAMBODIAN PAW SHIELD CO., LTD: គម្រោងបង្កើតរោងចក្រផលិតសម្ភារៈប្រើប្រាស់សត្វចិញ្ចឹម មានទីតាំងស្ថិតនៅអគារលេខ #I-4A-12 ភូមិព្រៃកសង្កែ ឃុំទឹកថ្លា ស្រុកព្រៃនប់ ខេត្តព្រះសីហនុ និងមានទុនវិនិយោគប្រមាណ ៥,៥លានដុល្លារអាមេរិក។

៥. X.Y.H. (CAMBODIA) GARMENT CO., LTD: គម្រោងបង្កើតរោងចក្រកាត់ដេរសម្លៀកបំពាក់ មានទីតាំងស្ថិតនៅភូមិសន្តិភាព ឃុំតាំងក្រូច ស្រុកសំរោងទង ខេត្តកំពង់ស្ពឺ និងមានទុនវិនិយោគប្រមាណ ៥,៤លានដុល្លារអាមេរិក៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖Kampucheathmey ចេញផ្សាយថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២២។*

## ទូតម៉ាឡេស៊ី៖ ច្បាប់វិនិយោគថ្មីរបស់កម្ពុជា បង្ហាញកាន់តែច្បាស់ ពីការលើកទឹកចិត្តដល់វិនិយោគិន




*ដោយ Kampucheathmey*

ឯកអគ្គរដ្ឋទូតម៉ាឡេស៊ីប្រចាំកម្ពុជា បានលើកអំពីច្បាប់ស្តីពីវិនិយោគថ្មីនៃព្រះរាជាណាចក្រកម្ពុជា ថាអាចចាប់យកកាលានុវត្តភាពជាអតិបរមា ក្នុងការជំរុញវិនិយោគិនបរទេសមកបណ្តាក់ទុននៅកម្ពុជា ឱ្យកាន់តែមានសន្ទុះទៅមុខជាបន្តបន្ទាប់។ លោកក៏បានសម្តែងអំណរសាទរ និងវាយតម្លៃខ្ពស់ ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ក្រុម-ប្រឹក្សាអភិវឌ្ឍន៍កម្ពុជា និងក្រសួងស្ថាប័នពាក់ព័ន្ធ ដែលបានតាក់តែងច្បាប់នេះឡើង។ ច្បាប់នេះ បានបង្ហាញកាន់តែច្បាស់ពីការលើកទឹកចិត្តដល់វិនិយោគិនក្នុងស្រុក និងបរទេស ហើយក៏ផ្តោតសំខាន់លើនិន្នាការធុរកិច្ចសកល ដោយបានដាក់បញ្ចូលវិស័យឧស្សាហកម្មបៃតង បច្ចេកវិទ្យាព័ត៌មាន និងទូរគមនាគមន៍ និងឧស្សាហកម្មដែលមានបច្ចេកវិទ្យាខ្ពស់។ រាល់ប្បញ្ញត្តិក្នុងច្បាប់នេះសុទ្ធតែបង្ហាញពីកិច្ចសម្រួល តាមរយៈការលើកលែងពន្ធក្នុងកញ្ចប់លើកទឹកចិត្ត និងការការពារវិនិយោគសំដៅធ្វើឱ្យកាន់តែមានភាពងាយស្រួល រលូន និងប្រសិទ្ធភាព ក្នុងការអនុវត្តនីតិវិធី ចុះបញ្ជីសម្រាប់ក្រុម-ហ៊ុនវិនិយោគ។ រាជរដ្ឋាភិបាលកម្ពុជា នឹងទទួលបាននូវលទ្ធផលផ្លែផ្កា នៅក្នុងរយៈពេលខ្លីខាងមុខ។

ទន្ទឹមនេះដែរ អគ្គលេខាធិការ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានគូសបញ្ជាក់ពីភាពចាំបាច់របស់កម្ពុជា ក្នុងការកែ

លម្អបរិស្ថានវិនិយោគ សំដៅជំរុញទាក់ទាញការវិនិយោគក្នុងគន្លងប្រក្រតីភាពថ្មីនៃវិបត្តិជំងឺកូវីដ-១៩ ដែលទាមទារឱ្យកម្ពុជាប្រកាន់យកនូវអភិក្រមបុរេសកម្មជាងមុនក្នុងការជំរុញ និងទាក់ទាញវិនិយោគ ប្រកបដោយគុណភាព និងចីរភាព។ ច្បាប់នេះត្រូវបានតាក់តែងឡើង ដើម្បីឆ្លើយតបទៅនឹងការប្រែប្រួលនៃភូមិសាស្ត្រនយោបាយ និងសេដ្ឋកិច្ច បដិវត្តន៍ឧស្សាហកម្ម ៤.០ បរិវត្តកម្មឌីជីថល និងការអោក់អេួលនៃខ្សែសង្វាក់តម្លៃសាកល ដែលបណ្តាលមកពីការរាតត្បាតនៃជំងឺកូវីដ-១៩ សំដៅចាប់យកកាលានុវត្តភាពជាអតិបរមាពីនិម្មាបនកម្មសេដ្ឋកិច្ចក្នុងតំបន់ ដែលកំពុងវិវត្តយ៉ាងឆាប់រហ័ស។

ប្រធានសភាធុរកិច្ចម៉ាឡេស៊ីនៅកម្ពុជា បានលើកឡើងថា ច្បាប់ស្តីពីវិនិយោគ នៃព្រះរាជាណាចក្រកម្ពុជា នឹងក្លាយជាមូលដ្ឋានច្បាប់ និងបទប្បញ្ញត្តិដ៏រឹងមាំមួយសម្រាប់ទាក់ទាញវិនិយោគផ្ទាល់ពីបរទេស និងជួយជំរុញដល់ការលូតលាស់សេដ្ឋកិច្ចរបស់កម្ពុជា។

គួរកត់សម្គាល់ថា គិតត្រឹមដំណាច់ឆ្នាំ២០២១ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បានទទួលស្វាគមន៍ និងចុះបញ្ជីគម្រោងវិនិយោគមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ របស់ម៉ាឡេស៊ី មានចំនួន ១៦២គម្រោង ដែលមានទុនវិនិយោគសរុបប្រមាណ ៣,១៥ ប៊ីលានដុល្លារអាមេរិក៕

*ដោយ ម៉ែន ខែមរៈ*

## តារាងប្រចាំសប្តាហ៍

### តារាងទី១៖ ចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេសក្នុងរយៈពេល១១ខែ ឆ្នាំ២០២១

ទិន្នន័យរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុកម្ពុជា បង្ហាញថានៅក្នុងរយៈពេល១១ខែ ឆ្នាំ២០២១ រដ្ឋបាលថ្នាក់ជាតិ បានប្រមូលចំណូលពន្ធលើពាណិជ្ជកម្មក្រៅប្រទេសសរុបចំនួន ១ ៨២៨,៤៦ប៊ីលានរៀល ថយចុះប្រមាណជា៦,៦% ធៀបនឹងរយៈពេលដូចគ្នា នៅឆ្នាំ២០២០។

ជាក់ស្តែង ការប្រមូលចំណូលពន្ធ និងអាករលើការនាំចូលបានសរុបចំនួន ១ ៧៨៨,៨០ប៊ីលានរៀល នៅក្នុងរយៈពេល១១ខែឆ្នាំ២០២១ ថយចុះប្រហែលជា ៧,៧% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២០។

ក៏ប៉ុន្តែ ការប្រមូលចំណូលពន្ធ និងអាករលើការនាំចេញបានសរុបចំនួន ៣៧,៦៦ប៊ីលានរៀល នៅក្នុងរយៈពេល ១១ខែ ឆ្នាំ២០២១ កើនឡើងយ៉ាងខ្លាំងប្រហែលជា ១០០,៦% ធៀបនឹងរយៈពេលដូចគ្នាឆ្នាំ២០២០៕

*ដោយ មិត្ត ចន្ទី*

| បរិយាយ(គិតជាប៊ីលានរៀល) | ១១ខែ ឆ្នាំ២០២០ | ១១ខែ ឆ្នាំ២០២១ | ការប្រែប្រួល% |
|---|---|---|---|
| ចំណូលពន្ធលើ ពាណិជ្ជកម្មក្រៅប្រ ទេស | 1,956.48 | 1,826.46 | -6.6% |
| ពន្ធ និងអាករលើការនាំចូល | 1,937.71 | 1,788.80 | -7.7% |
| ពន្ធ និងអាករលើការនាំចេញ | 18.77 | 37.66 | 100.6% |

*ប្រភព៖តារាងប្រតិបត្តការហិរញ្ញវត្ថុសម្រាប់ខែវិច្ឆិកា ឆ្នាំ២០២០ និង២០២១នៃក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ*

### តារាងទី២៖ ពាណិជ្ជកម្មរវាងកម្ពុជា និងប្រទេសថៃលើមុខទំនិញ នៅក្នុងខែធ្នូ ឆ្នាំ២០២១

យោងទៅតាមទិន្នន័យរបស់ធនាគារជាតិប្រទេសថៃ បានបង្ហាញថា នៅខែធ្នូ ឆ្នាំ២០២១ ទំហំពាណិជ្ជកម្មរវាងប្រទេសកម្ពុជា និងប្រទេសថៃ មានទំហំទឹកប្រាក់សរុប ៦៧១លានដុល្លារ កើនឡើងប្រមាណជា ៤,៥% បើធៀបនឹងខែវិច្ឆិកា ឆ្នាំ២០២១។

ជាក់ស្តែង ការនាំចេញទំនិញរបស់កម្ពុជាទៅប្រទេសថៃ មានទំហំទឹកប្រាក់សរុប ៧៧,៨២លានដុល្លារ នៅ ខែធ្នូ ឆ្នាំ២០២១ ដែលមានកំណើនប្រមាណជា១៦,១% បើធៀបនឹងខែវិច្ឆិកា ឆ្នាំ២០២១។

ស្របពេលនោះដែរ ការនាំចូលទំនិញរបស់ប្រទេសថៃមកកម្ពុជា មានទំហំទឹកប្រាក់សរុប ៥៩៣,១៨លានដុល្លារ នៅខែធ្នូឆ្នាំ២០២១ និងមានកំណើនប្រមាណជា ៣,២% បើធៀបនឹងខែវិច្ឆិកា ឆ្នាំ២០២១។

*ដោយ មិត្ត ចន្ទី*

***ឯកតា៖ គិតជាលានដុល្លារអាមេរិក***

| បរិយាយ | មករា | កុម្ភៈ | មីនា | មេសា | ឧសភា | មិថុនា | កក្កដា | សីហា | កញ្ញា | តុលា | វិច្ឆិកា | ធ្នូ |
|---|---|---|---|---|---|---|---|---|---|---|---|---|
| **ទំហំពាណិជ្ជកម្ម** | **653.39** | **644.76** | **799.19** | **596.61** | **671.83** | **616.20** | **630.47** | **625.27** | **732.42** | **691.86** | **642.03** | **671.00** |
| កំណើន% | | -1.3% | 24.0% | -25.3% | 12.6% | -8.3% | 2.3% | -0.8% | 17.1% | -5.5% | -7.2% | 4.5% |
| កម្ពុជានាំចេញទៅថៃ | 113.22 | 112.05 | 104.27 | 72.63 | 57.65 | 55.93 | 52.97 | 54.51 | 63.79 | 59.03 | 67.03 | 77.82 |
| កំណើន% | | -1.0% | -6.9% | -30.3% | -20.6% | -3.0% | -5.3% | 2.9% | 17.0% | -7.5% | 13.6% | 16.1% |
| ថៃនាំចូលមកកម្ពុជា | 540.17 | 532.71 | 694.92 | 523.98 | 614.18 | 560.27 | 577.50 | 570.76 | 668.63 | 632.83 | 575.00 | 593.18 |
| កំណើន% | | -1.4% | 30.4% | -24.6% | 17.2% | -8.8% | 3.1% | -1.2% | 17.1% | -5.4% | -9.1% | 3.2% |

ប្រភព៖ *ធនាគារជាតិប្រទេសថៃ*

## ព័ត៌មាន និងទិន្នន័យរបស់បណ្តាប្រទេសនៅក្នុងអាស៊ាន និងដៃគូពាណិជ្ជកម្មដទៃទៀត

### អ៊ីរ៉ង់ ត្រៀមខ្លួនរួចជាស្រេចសហការជាមួយក្រសួងរ៉ែ និងថាមពល ក្នុងការស្វែងរុករក រ៉ែ ថាមពល និងប្រេងកាតនៅកម្ពុជា



*ដោយ CNC*

រដ្ឋអ៊ីស្លាមអ៊ីរ៉ង់ជាប្រទេសមួយ ដែលនាំប្រេងចេញលក់ដ៏ធំមួយទៅក្រៅប្រទេស។ នៅក្នុងជំនួបការងារជាមួយរដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល នៅថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២២ ឯកអគ្គរដ្ឋទូត នៃសាធារណរដ្ឋអ៊ីស្លាមអ៊ីរ៉ង់ប្រចាំកម្ពុជា បានលើកឡើងថា សាធារណរដ្ឋអ៊ីស្លាមអ៊ីរ៉ង់ បានត្រៀមខ្លួនរួចជាស្រេច ដើម្បីធ្វើការងារសហការជាមួយក្រសួងរ៉ែ និងថាមពលកម្ពុជា ក្នុងស្វែងរុករកវិស័យរ៉ែ ថាមពល និងប្រេងកាតនៅកម្ពុជា។

រដ្ឋមន្ត្រីក្រសួងរ៉ែ និងថាមពល បានមានប្រសាសន៍ថា កម្ពុជាបានធ្វើកិច្ចសហប្រតិបត្តិការលើវិស័យប្រេងកាត រួមមាន ការវិនិយោគ និងការអភិវឌ្ឍប្លុកប្រេងកាតរបស់កម្ពុជា ដែលមានស្រាប់ និងការសិក្សាស្វែងរុករកប្រេង និងឧស្ម័នបន្ថែម, គម្រោងសិក្សាសមិទ្ធិលទ្ធភាពនៃការរៀបចំរោងចក្រចម្រាញ់ប្រេងកាតនៅកម្ពុជា ក៏ដូចជាជំនួយបច្ចេកទេស និងការបណ្តុះបណ្តាលធនធានមនុស្សក្នុងវិស័យប្រេងកាត, កិច្ចសហប្រតិបត្តិការពាណិជ្ជកម្មថាមពល ការកៀងគរការវិនិយោគ និងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធអគ្គិសនី៕ *ម៉ែន ខែមរៈ*

*ប្រភព ៖ CNC ចេញផ្សាយថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២២។*

### ការបញ្ជាទិញសម្រាប់ការនាំចេញរបស់តៃវ៉ាន់កើនឡើង ១១,៧%ក្នុងខែមករា ឆ្នាំ២០២២

នៅក្នុងខែមករា ឆ្នាំ២០២២ ការបញ្ជាទិញសម្រាប់ការនាំចេញរបស់តៃវ៉ាន់មានតម្លៃ៥៨,៩ប៊ីលានដុល្លារ កើនឡើង ១១,៧% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ២០២១ និងការរំពឹងទុកទីផ្សារថា នឹងមានកំណើន ១២% នៅខែមករា។

នៅក្នុងការបញ្ជាទិញទាំងនោះ រួមមាន៖ ផលិតផលអេឡិចត្រូនិចកើនឡើង ១៣,៥% ផលិតផលព័ត៌មាន និងទំនាក់ទំនង (Information and Communication Products) កើនឡើង ៣,៩%, ផលិតផលមូលដ្ឋាន និងលោហធាតុ (Basic Metals and Articles Thereof) មានកំណើនរហូតដល់ ៣៦,១% និងផ្លាស្ទិច កៅស៊ូ (Plastic Robbers and Articles Thereof) កើន

ឡើង ១២,១% និងផលិតផលផ្សេងៗទៀតកើនឡើង ៦%។

ក្នុងចំណោមដៃគូពាណិជ្ជកម្មសំខាន់ៗ ការបញ្ជាទិញបានកើនឡើងច្រើនជាងគេបំផុតគឺប្រទេសជាសមាជិកអាស៊ានដែលមានរហូតដល់ ៣០,៦% សហរដ្ឋអាមេរិក ១៨,៦% ចិន និងហុងកុង ៨,៩% និងជប៉ុន ០,៧% ចំណែកឯ អឺរ៉ុបការបញ្ជាទិញបានធ្លាក់ចុះ -១,២%។

*ដោយ មុំ ចិន្តា*

*ប្រភព៖ Ministry of Economic Affairs, R.O.C.*

## រដ្ឋាភិបាលវៀតណាមនឹងកាត់បន្ថយពន្ធលើប្រេង និងកម្រៃសេវា ដើម្បីទប់ការឡើងថ្លៃប្រេង




*កាលពីថ្ងៃទី១១ ខែកុម្ភៈ តម្លៃប្រេងនៅប្រទេសវៀតណាមបានកើនឡើងដល់ជិត ១ ០០០ដុងក្នុងមួយលីត្រ គឺជាកម្រិតមួយខ្ពស់បំផុតដែលមិនធ្លាប់មានចាប់តាំងពីខែសីហា ឆ្នាំ២០១៤។ ប្រភព៖ VNA/VNS Photo Trần Việt*

កាលពីថ្ងៃទី១១ ខែកុម្ភៈកន្លងទៅ តម្លៃប្រេងលក់រាយនៅវៀតណាមបានកើនឡើងជិត ១ ០០០ដុង ក្នុងមួយលីត្រ នេះបើយោងតាមរបាយការណ៍រួមរបស់ក្រសួងពាណិជ្ជកម្ម ឧស្សាហកម្ម និងក្រសួងហិរញ្ញវត្ថុរបស់វៀតណាម។ ក្នុងនោះតម្លៃប្រេងឥន្ធនៈជីវឧស្ម័ន RON95 បានកើនឡើងពី ៩៦២ដុងដល់ទៅ ២៥ ៣២២ដុង (១,១២ដុល្លារសហរដ្ឋអាមេរិក) ក្នុងមួយលីត្រ គឺជាការកើនឡើងខ្ពស់បំផុតដែលមិនធ្លាប់មានចាប់តាំងពីខែសីហា ឆ្នាំ២០១៤មក។ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងឧស្សាហកម្មបាននិយាយថា ស្ថានីយ៍ប្រេងមួយចំនួននៅមានសាំងស្តុកទុកនៅឡើយ ប៉ុន្តែមិនព្រមលក់ ហើយបែរជាប្រកាសថាអស់សាំង ដើម្បីរង់ចាំការឡើងថ្លៃ។ លោកបានបន្ថែមថា ឈ្មួញកណ្តាលនឹងត្រូវទទួលការពិន័យយ៉ាងតឹងរ៉ឹង ប្រសិនបើមានការស្តុកប្រេងទុក ដែលបណ្តាលឱ្យតំបន់មួយចំនួនខ្វះខាតប្រេងឥន្ធនៈសម្រាប់ប្រើប្រាស់។ ហេតុនេះ លោកបានស្នើសុំឱ្យសហគ្រាសប្រេងឥន្ធនៈគោរពតាមបទបញ្ញត្តិស្តីពីការលក់ និងបញ្ជីសារពើភ័ណ្ឌ និងមិនត្រូវស្តុកប្រេង ដោយមិនបញ្ចេញលក់នោះឡើយ ព្រោះវានឹងនាំឱ្យប៉ះពាល់ដល់ការផ្គត់ផ្គត់ប្រេងនៅទីផ្សារក្នុងស្រុក។

ដើម្បីចាត់វិធានការលើករណីនេះ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងឧស្សាហកម្មបានចេញសេចក្តីសម្រេចបង្កើតក្រុមអធិការកិច្ចចំនួនបី ដើម្បីចុះធ្វើអធិការកិច្ចលើការផ្គត់ផ្គង់ប្រេងឥន្ធនៈនៅតាមមូលដ្ឋានមួយចំនួន។ បន្ថែមពីនោះ ក្រសួងពាណិជ្ជកម្ម និងឧស្សាហកម្មក៏បានស្នើឱ្យគណៈកម្មាធិការប្រជាជនប្រចាំខេត្តនីមួយៗបង្កើនការត្រួតពិនិត្យ និងធ្វើអធិការកិច្ចលើស្ថានីយ៍លក់ប្រេងដែលស្ថិតក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលខេត្តនីមួយៗ ដោយលោកបានស្នើឱ្យសហគ្រាសប្រេងឥន្ធនៈ ធ្វើការចែករំលែកការលំបាកជាមួយប្រជាពលរដ្ឋ ដែលមានចំនួនសរុបជិត ១០០លាននាក់ និងបានស្នើសុំឱ្យសហគ្រាសទាំងនោះគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់រាជរដ្ឋាភិបាល ដើម្បីធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចរបស់ជាតិទាំងមូល។

ទន្ទឹមនេះដែរ រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងឧស្សាហកម្មបានបន្ថែមថា រដ្ឋាភិបាលគួរតែចូលរួមចំណែកចែករំលែកបន្ទុករបស់សហគ្រាសប្រេងដែលកំពុងតែជួបការលំបាក។ នៅក្នុងន័យនេះ ប្រសិនបើតម្លៃប្រេងនៅតែបន្តកើនឡើង រដ្ឋាភិបាលវៀតណាមត្រូវកាត់បន្ថយពន្ធ និងកម្រៃសេវាប្រេង ដើម្បីរក្សាស្ថិរភាពតម្លៃប្រេង

នៅលើទីផ្សារ ដោយសារការកើនឡើងតម្លៃប្រេងបាន ធ្វើឱ្យសន្ទស្សន៍តម្លៃអ្នកប្រើប្រាស់ (Consumer Price Index, CPI) មានការប្រែប្រួលយ៉ាងខ្លាំង គឺកើនឡើង ដល់ទៅ ១,៩៤% នៅក្នុងខែមករា។ ហេតុនេះទាមទារ ឱ្យរដ្ឋាភិបាលត្រូវតែពិចារណាពីគុណសម្បត្តិ និងគុណ វិបត្តិ ដើម្បីការពារផលប្រយោជន៍ទូទៅរបស់ប្រជាពល រដ្ឋ និងសហគ្រាស។ បើពុំដូច្នេះទេ រដ្ឋនឹងទទួលរងសំ ពាធពីសាធារណៈជន។

លោកបានធ្វើការកត់សម្គាល់ថា ប្រសិនបើតម្លៃប្រេងឆៅ កើនឡើងលើសពី ១០០ដុល្លារសហរដ្ឋអាមេរិក ក្នុង មួយបារ៉ែលនោះ បន្ថែមពីលើវិធានការមូលនិធិជានាស្ថិរ ភាពតម្លៃប្រេង រដ្ឋាភិបាលវៀតណាមចាំបាច់ត្រូវតែកាត់ បន្ថយពន្ធ និងថ្លៃដើម ដើម្បីទប់តម្លៃប្រេងឱ្យមានស្ថិរ ភាព។ ព្រោះបើកាលណាតម្លៃប្រេងហក់ឡើងខ្លាំង វា នឹងធ្វើឱ្យប៉ះពាល់ដល់ការស្តារសេដ្ឋកិច្ចឡើងវិញ ក៏រួម ទាំងគោលនយោបាយកាត់បន្ថយពន្ធលើតម្លៃបន្ថែម (VAT) ២% ផងដែរ។

ប៉ុន្តែទោះជាយ៉ាងណាក្តី ស្ថានភាពនេះហាក់មានភាព ល្អប្រសើរជាងដើមខែកុម្ភៈ។ ព្រោះគម្រោងប្រេងឥន្ធនៈ គឺមីរបស់វៀតណាមបានបំពេញតម្រូវការក្នុងស្រុកបាន ជាង ៧០% ឯណោះ។ ប៉ុន្តែតំបន់មួយចំនួននៅតាម មូលដ្ឋាននៅតែខ្វះខាតប្រេងឥន្ធនៈ សម្រាប់ប្រើប្រាស់ ដោយសាររោងចក្រចំរាញ់ប្រេងរបស់វៀតណាម Nghi Sơn Oil Refinery ផលិតបានតែពាក់កណ្តាលប៉ុណ្ណោះ ព្រោះប្រេងនាំចូលមិនទាន់មកដល់។ ម្យ៉ាងទៀត ដោយ សារតែកត្តាភូមិសាស្ត្រនយោបាយទាក់ទងនឹងជម្លោះ របស់រុស្ស៊ីនៅអ៊ុយក្រែន បានធ្វើឱ្យតម្លៃប្រេងលើពិភព-លោកមានការប្រែប្រួលយ៉ាងខ្លាំង ដែលជាហេតុនាំឱ្យ ប៉ះពាល់ដល់តម្លៃប្រេងនៅក្នុងស្រុក។ បន្ថែមពីនោះទៀត ទុនបម្រុងប្រេងឥន្ធនៈដែលរដ្ឋាភិបាលបម្រុងទុកមាន ចំនួនតិចតួច។ ម្យ៉ាងទៀត ការកក់ប្រេងទុក គឺជារឿងដ៏ លំបាកសម្រាប់វៀតណាម ដោយសារតែឃ្លាំង និងកំពង់ ផែរបស់វៀតណាមនៅមានកម្រិត ខណៈដែលរដ្ឋាភិ-បាលវៀតណាមមិនមានប្រភពរូបិយបណ្ណបរទេសគ្រប់ គ្រាន់ដើម្បីនាំចូលប្រេង។

សេដ្ឋវិទូ លោក Đinh Trọng Thịnh បានបង្ហាញថា លក្ខខណ្ឌស្តុកប្រេងឥន្ធនៈបម្រុងទុកតម្រូវឱ្យរដ្ឋាភិបាល ពិចារណាយ៉ាងហ្មត់ចត់លើលក្ខខណ្ឌអាកាសធាតុ ដើម្បី ការពារភ្លើងឆេះ ការផ្ទុះ និងត្រូវគោរពក្បួនខ្នាតភូគព្ភ វិទ្យា ថែមទាំងតម្រូវឱ្យរដ្ឋាភិបាលពិចារណាពីកត្តាសន្តិ សុខ នយោបាយ និងសង្គមថែមទៀតផង។ លោកបាន បន្ថែមថា ប្រសិនបើវៀតណាមមានទុនបម្រុងប្រេង ឥន្ធនៈគ្រប់គ្រាន់ ដូចបណ្តាប្រទេសផ្សេងទៀតនៅលើ ពិភពលោក នោះការផ្គត់ផ្គង់ប្រេងនៅវៀតណាមនឹងមាន ភាពសកម្ម ហើយរដ្ឋាភិបាលនឹងអាចមានលទ្ធភាពអន្ត-រាគមន៍បានភ្លាមៗចំពោះការប្រែប្រួលទីផ្សារប្រេងទាំង អស់។

សេដ្ឋវិទូ Đinh Trọng Thịnh បាននិយាយទៀតថា ការ ព្យាករណ៍ និងការតាមដាននិន្នាការតម្លៃប្រេងលើពិភព-លោក គឺជាបញ្ហាប្រឈមមួយទៀតរបស់វៀតណាម ដោយសារ បច្ចុប្បន្ននេះ ប្រទេសវៀតណាមនៅមាន ភាពទន់ខ្សោយនៅក្នុងការកសាងទិន្នន័យ និងធនធាន មនុស្សក្នុងការវិភាគ និងព្យាករណ៍ទីផ្សារ។ ហេតុនេះ លោកបានផ្តល់យោបល់ឱ្យរដ្ឋាភិបាលវៀតណាមត្រូវ ផ្តោតលើការកសាងធនធានមនុស្សផ្នែកនេះ។ លោកក៏ បានបន្ថែមទៀតថា ការចរចារលក់ និងទិញប្រេងត្រូវតែ ធ្វើឡើងក្នុងរយៈពេលបីខែ ប្រាំមួយខែ ឬមួយឆ្នាំ និង ត្រូវតែកសាងឱ្យមានទិន្នន័យរួមមួយដែលមានផ្ទុករាល់

ទិន្នន័យផ្គត់ផ្គង់ តម្រូវការ និងផលប៉ះពាល់របស់ភូមិសាស្ត្រនយោបាយ ដែលបង្កឱ្យមានគុណសម្បត្តិ ឬគុណវិបត្តិនានា។ លោកបានផ្តល់អនុសាសន៍ថា ដោយសារតែមូលនិធិធានាស្ថិរភាពតម្លៃប្រេងរបស់វៀតណាមមានរយៈពេលខ្លី ដូចនេះរដ្ឋាភិបាលគួរតែបើកចំហរទីផ្សារប្រេង ដើម្បីឱ្យតម្លៃប្រេងក្នុងស្រុកប្រកៀកប្រកិតនឹងតម្លៃប្រេងរបស់ពិភពលោក។ ចំណែកឯការកែសម្រួលតម្លៃប្រេងឥន្ធនៈនៅក្នុងស្រុកវិញ គួរតែធ្វើឡើងនៅក្នុងចន្លោះពីប្រាំទៅប្រាំពីរថ្ងៃ៕ *ដោយ វង្ស ច័ន្ទរស្មីដារា*

*ប្រភព៖ [Vietnam News](Vietnam News) ចេញផ្សាយ ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២២*

## ក្រុមប្រឹក្សាអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គម (NESDC) មានភាពសុទិដ្ឋិនិយមលើការរំពឹងទុកចំពោះកំណើនសេដ្ឋកិច្ចរបស់ថៃ



*មនុស្សម្នាពិនិត្យមើលផលិតផលប្រើប្រាស់ក្នុងពិព័រណ៍មួយ ដែលប្រារព្ធធ្វើនៅការិយាល័យរដ្ឋលេខាធិការអចិន្ត្រៃយ៍ក្រសួងការពារជាតិកាលពីថ្ងៃច័ន្ទ។ សហការរៀបចំដោយហាង Thong Fah (Blue Flag) របស់នាយកដ្ឋានពាណិជ្ជកម្មក្នុងស្រុក និងក្រសួងការពារជាតិ។ ប្រភព៖ Bangkok Post Photo: Apichart Jinakul*

ក្រុមប្រឹក្សាជាតិអភិវឌ្ឍន៍សេដ្ឋកិច្ច និងសង្គមរបស់ថៃ (The National Economic and Social Development Council) បានរក្សាការព្យាករណ៍កំណើនសេដ្ឋកិច្ចរបស់ខ្លួនក្នុងរង្វង់ពី ៣,៥% ទៅ ៤,៥% ដោយរំពឹងទុកថា ផែនការរបស់រាជរដ្ឋាភិបាលនៅក្នុងការទប់ស្កាត់ការរីករាលដាលអូមីក្រុងនឹងទទួលបានភាពជោគជ័យ និងបានរំពឹងថា នឹងពុំមានវិធានការរឹតបន្តឹងថែមទៀតទេ។ ការព្យាករណ៍នេះ រំពឹងថា តម្រូវការក្នុងស្រុកនឹងមានការកើនឡើង វិស័យទេសចរណ៍ក្នុងប្រទេសថៃនឹងងើបឡើងវិញ ចំណែកឯការនាំចេញនឹងបន្តកើនឡើង ហើយការវិនិយោគសាធារណៈក៏នឹងអាចកើនឡើងខ្ពស់ផងដែរ។

នៅក្នុងឆ្នាំ២០២២ ការនាំចេញរបស់ថៃត្រូវបានរំពឹងថា នឹងកើនឡើង ៤,៩% ខណៈដែលការប្រើប្រាស់ក្នុងវិស័យឯកជនត្រូវបានរំពឹងថា នឹងកើនឡើង ៤,៥% និងការវិនិយោគនៅក្នុងវិស័យឯកជន ត្រូវបានរំពឹងថា កើនឡើងចំនួន ៣,៨%។ ដោយឡែកការវិនិយោគសាធារណៈត្រូវបានរំពឹងថា នឹងកើនឡើង ៤,៦% ជាមួយនឹងអត្រាអតិផរណាស្ថិតក្នុងចន្លោះពី ១,៥% ទៅ ២,៥%។ ខណៈគណីចរន្តត្រូវបានព្យាករណ៍ថា នឹងមានអតិរេកចំនួន ១,៥% នៃផ.ស.ស។ ចំណែកឯចំនួនភ្ញៀវទេសចរអន្តរជាតិនៅក្នុងឆ្នាំ២០២២ ត្រូវបានរំពឹងទុកថា អាចនឹងកើនឡើងដល់ ៥លាននាក់ ដែលកត្តានេះអាចនឹងបង្កើនចំណូលដល់ពលរដ្ឋថៃចំនួន ៤៦០ប៊ីលានបាត។ ដោយឡែក លោក Danucha Pichayanan អគ្គលេខាធិការរបស់ NESCS បាននិយាយថា ភាពមិនច្បាស់លាស់ ឬភាពមិនទៀងទាត់នៃផលប៉ះពាល់របស់អូមីក្រុងនឹងនៅតែបន្តកើតមាន។ ដូចនេះ លោកបានផ្តល់អនុសាសន៍ថា នៅក្នុងឆ្នាំ២០២២ រដ្ឋាភិបាលត្រូវតែបន្តផ្តោតការយកចិត្តទុកដាក់លើការទប់ស្កាត់ការរីករាលដាលកូវីដ-១៩ និងការពារកុំឱ្យការឆ្លងរីករាលដាលនៃជំងឺនេះផ្ទុះឡើងវិញ។ បន្ថែមពីនោះ រដ្ឋាភិបាលត្រូវជួយដល់អាជីវកម្ម និងវិស័យដែលរងផលប៉ះពាល់ដោយសារកូវីដ-១៩ ដែលកំពុងតែពិបាកស្តារឡើងវិញ។ ទន្ទឹមនេះទៀត ត្រូវរក្សាកំណើនចំណាយនៅក្នុងស្រុក និង

ត្រូវចាត់វិធានការដោះស្រាយបំណុលរបស់ពលរដ្ឋ ព្រមទាំងជម្រុញដល់ការនាំចេញ។

លោកបានបន្តថា រដ្ឋាភិបាលត្រូវជម្រុញដល់ការវិនិយោគឯកជន រក្សាកំណើនចំណាយ និងកំណើនការវិនិយោគសាធារណៈរបស់រដ្ឋ ដោយធ្វើការត្រួតពិនិត្យ និងត្រៀមខ្លួនរួចជាស្រេចដើម្បីឆ្លើយតបចំពោះបំរែបំរួលសេដ្ឋកិច្ចនៅក្នុងពិភពលោក។ ជាចុងបញ្ចប់ រដ្ឋាភិបាលត្រូវផ្តោតការយកចិត្តទុកដាក់លើការស្តារសេដ្ឋកិច្ចឡើងវិញ ដើម្បីពង្រឹងការប្រកួតប្រជែង និងធ្វើការកែលម្អការបែងចែកប្រាក់ចំណូលឱ្យកាន់តែល្អប្រសើរ និងគួរបន្តកាត់បន្ថយកាបូននៅក្នុងបរិយាកាសឱ្យបានទាបបំផុត៕

*ដោយ វង្ស ច័ន្ទរស្មីដារា*

*ប្រភពៈ Bangkok Post ចេញផ្សាយ ថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២២*

## ក្រោយដកខ្លួនពីមីយ៉ាន់ម៉ា ក្រុមហ៊ុនភេសជ្ជៈជប៉ុន Kirin ងាកទៅរកការផលិតនៅអាមេរិក និងអូស្ត្រាលី




*ដោយ ខេមបូណូមីស*

នៅក្នុងសប្តាហ៍កន្លងទៅនេះ ក្រុមហ៊ុនផលិតភេសជ្ជៈដ៏ធំរបស់ជប៉ុន Kirin Holdings បានប្រកាសថា នឹងដកខ្លួនចេញពីការបណ្តាក់ទុនជាមួយក្រុមហ៊ុនប្រទេសមីយ៉ាន់ម៉ា និងចិន ក្រោមហេតុផល ទីផ្សារកំពុងមានភាពរអាក់រអួល ដោយសារអស្ថិរភាពនយោបាយ។ ក្រុមហ៊ុន Kirin នឹងលក់ភាគហ៊ុនរបស់ខ្លួនចេញពីក្រុមហ៊ុន China Resources Kirin Beverages ដោយដំណើការលក់ភាគហ៊ុននេះ មានតម្លៃជិត១ប៊ីលានដុល្លារ។

កាលពីឆ្នាំ ២០១៥ ក្រុមហ៊ុន Kirin បានទិញភាគហ៊ុនក្រុមហ៊ុនស្រាបៀរមីយ៉ាន់ម៉ា គឺក្រុមហ៊ុន Myanmar Brewery និងជាដៃគូបណ្តាក់ទុនរួមគ្នាគឺក្រុមហ៊ុន Myanmar Economic Holdings ដែលជាក្រុមហ៊ុនមានជាប់ទាក់ទងនឹងយោធាមីយ៉ាន់ម៉ា។ ប៉ុន្តែ ដោយសារតែ វិបត្តិនយោបាយនៅមីយ៉ាន់ម៉ា បានកើនឡើងនៅក្រោយពីការធ្វើរដ្ឋប្រហារ បានបង្ខំឱ្យក្រុមហ៊ុននេះ ត្រូវដកខ្លួនចេញពីមីយ៉ាន់ម៉ា ដែលស្ថិតក្រោមរបបយោធាមីយ៉ាន់ម៉ាតែម្តង ដោយគ្រោងនឹងបញ្ចប់ការបណ្តាក់ទុននៅត្រឹមខែមិថុនាខាងមុខនេះ។ បច្ចុប្បន្ន ក្រុមហ៊ុនជប៉ុនមួយនេះ កំពុងស្វែងរកការបង្វែរប្រាក់ចំណូលពីការលក់ទ្រព្យសកម្មនៅមីយ៉ាន់ម៉ា ឆ្ពោះទៅរកការអភិវឌ្ឍអាជីវកម្មផលិតស្រាបៀរ និងផលិតផលសុខភាពនៅសហរដ្ឋអាមេរិក និងអូស្ត្រាលីវិញម្តង។

កាលពីខែធ្នូ ឆ្នាំ២០២១ ក្រុមហ៊ុន Kirin បានបញ្ចប់ការទិញយកភាគហ៊ុនក្រុមហ៊ុនផលិតស្រាបៀរអូស្ត្រាលី Fermentum Group ក្នុងទំហំទឹកប្រាក់ជាង៣៤០លានដុល្លារផងដែរ។ មួយខែក្រោយមក Kirin ក៏បានទិញក្រុមហ៊ុនផលិតស្រាបៀររបស់អាមេរិក Bell's Brewery ក្នុងតម្លៃប្រហាក់ប្រហែលគ្នានេះដែរ។ ក្រុមហ៊ុន Kirin រំពឹងថា ការលក់ស្រាបៀរដែលនឹងផលិតឡើងនៅទីផ្សារអាមេរិក និងអូស្ត្រាលី អាចជួយបង្កើនប្រាក់ចំណេញកាន់តែច្រើនផងដែរនាពេលខាងមុខ៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភពៈខេមបូណូមីស ចេញផ្សាយថ្ងៃទី១៨ ខែកុម្ភៈ ឆ្នាំ២០២២។*

*ប្រភពៈKampucheathmeyចេញផ្សាយថ្ងៃទី២១ខែកុម្ភៈឆ្នាំ២០២២។*

## កម្ពុជា និងហុងគ្រី សហការវិនិយោគលើកកម្ពស់ពាណិជ្ជកម្មជាមួយគ្នា



*ដោយ Kampucheathmey*

កម្ពុជា និងហុងគ្រី បានបើកជំនួបធុរកិច្ចតាមប្រព័ន្ធវីដេអូក្រោមមូលបទ "ការតភ្ជាប់ធុរកិច្ចកម្ពុជា-ហុងគ្រី គន្លឹះក្នុងការជំរុញភាពជាដៃគូសេដ្ឋកិច្ច សម្រាប់ការស្តារសេដ្ឋកិច្ចប្រកបដោយភាពធន់ ពីជំងឺរាតត្បាតសកលកូវីដ-១៩"។ ក្នុងជំនួបនេះ មានការចូលរួមពីរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្មកម្ពុជា និងអនុរដ្ឋមន្ត្រីនៃក្រសួងការបរទេស និងពាណិជ្ជកម្មហុងគ្រី និងមានតំណាងមកពីវិស័យឯកជនសរុបប្រមាណ ២០០រូប ដែលក្នុងនោះ មកពីក្រុមហ៊ុនកម្ពុជាប្រមាណជា១០០ក្រុមហ៊ុន និងក្រុមហ៊ុនហុងគ្រីចំនួន២៨ ក្រុមហ៊ុន។

ជំនួបធុរកិច្ចនេះ ត្រូវបានរៀបចំឡើង ក្នុងគោលបំណងផ្តល់ឱកាសឱ្យធុរជន និងវិនិយោគិននៃប្រទេសទាំងពីរស្វែងយល់បន្ថែមពីសក្តានុពលពាណិជ្ជកម្ម និងវិនិយោគ ដើម្បីលើកកម្ពស់ និងពង្រឹកប្រតិបត្តិការ ធុរកិច្ចនិងវិនិយោគនៅប្រទេសទាំងពីរ និងដើម្បីសម្រេចបាននូវការស្តារសេដ្ឋកិច្ច និងកំណើនប្រកបដោយបរិយាប័ន្ន និងចីរភាព ដោយបានផ្តោតសំខាន់លើវិស័យសក្តានុពលចំនួន ០៦ រួមមាន៖ ១)កសិកម្ម និងផលិតផលកសិកម្ម ២)បច្ចេកវិទ្យាជារាសាស្ត្រ និងបរិស្ថាន ៣)ការកែច្នៃ និងសុវត្ថិភាពម្ហូបអាហារ ៤)សេវាកម្មទេសចរណ៍ ៥) ផលិតផលឱសថ និងបច្ចេកវិទ្យាវេជ្ជសាស្ត្រ និង ៦) ផលិតផលកម្មន្តសាល។

តាមរយៈវេទិកានេះ ភាគីកម្ពុជាបានបង្ហាញពីការត្រៀមខ្លួនរួចជាស្រេច ក្នុងការស្វាគមន៍ និងសម្រួលដល់ការធ្វើពាណិជ្ជកម្ម និងវិនិយោគ ដល់ធុរជននិងវិនិយោគិនហុងគ្រី ដែលមានបំណងមកពង្រីកប្រតិបត្តិការធុរកិច្ចនិងវិនិយោគ នៅកម្ពុជា ក្នុងពេលបច្ចុប្បន្ន និងនាពេលអនាគត៕ *ដោយ ម៉ែន ខេមរៈ*

*ប្រភព ៖ Kampucheathmey ចេញផ្សាយថ្ងៃទី១៧ ខែកុម្ភៈ ឆ្នាំ២០២២។*

# សេដ្ឋកិច្ចសកល

## ចិនច្រានចោល និងរិះគន់អាមេរិកជុំវិញការចោទប្រកាន់ជុំវិញរឿងពាណិជ្ជកម្ម



*ដោយ ខេមបូណ្ឌមីស*

ប្រទេសចិន បានរុញច្រានចោលការចោទប្រកាន់របស់សហរដ្ឋអាមេរិកដែលថា ទីក្រុងប៉េកាំងមិនបានធ្វើតាមការប្តេជ្ញាចិត្តបើកទីផ្សាររបស់ខ្លួន ដើម្បីចាប់ផ្តើមកិច្ចចរចាឡើងវិញស្តីពី ការបញ្ចប់សង្គ្រាមពន្ធគយ។ ដែលនេះគឺ អាមេរិកកំពុងបង្កើតមធ្យោបាយថ្មី ដើម្បីដោះស្រាយជាមួយនឹងយុទ្ធសាស្ត្រពាណិជ្ជកម្មរបស់ចិន។

តំណាងពាណិជ្ជកម្មអាមេរិក បាននិយាយថា ទីក្រុងប៉េកាំង បានពង្រីកវិធីសាស្ត្រដែលដឹកនាំដោយរដ្ឋ និងមិនមែនជាលក្ខណៈសេដ្ឋកិច្ចទីផ្សារ ដូចដែលបានសន្យាបើកទីផ្សារ នៅពេលដែលចិនបានចូលរួមជាមួយអង្គការពាណិជ្ជកម្មពិភពលោកក្នុងឆ្នាំ២០០១។ ជុំវិញបញ្ហា

នេះ អ្នកនាំពាក្យក្រសួងពាណិជ្ជកម្មចិន បានចេញមុខឆ្លើយតបទៅវិញថា អាមេរិកលើកឡើងបែបនេះ គឺ ផ្ទុយស្រឡះពីការពិត។ សេដ្ឋកិច្ចទីផ្សារ មិនមែនមានតែមួយវិធីនោះទេ ក៏ប៉ុន្តែ វាមានគំរូសេដ្ឋកិច្ចទីផ្សារខុសៗគ្នាជាច្រើន។

ទោះជាយ៉ាងណាក៏ដោយ ប្រធានាធិបតីអាមេរិក ក៏ចង់ឱ្យទំនាក់ទំនងជាមួយទីក្រុងប៉េកាំងប្រសើរឡើងដែរ។ ទីក្រុងវ៉ាស៊ីនតោន កំពុងស្វែងរកយុទ្ធសាស្ត្រថ្មីដើម្បីប្រើប្រាស់ឧបករណ៍ពាណិជ្ជកម្មក្នុងស្រុក ដើម្បីប្រកួតប្រជែងដោយយុត្តិធម៌ជាមួយប្រទេសចិន។ ទាក់ទិននឹងយុទ្ធសាស្ត្រថ្មីនេះ អ្នកនាំពាក្យក្រសួងពាណិជ្ជកម្មចិន ក៏បានលើកឡើងដែរថា វិធីសាស្ត្ររបស់សហរដ្ឋអាមេរិក គួរតែធ្វើស្របទៅតាមច្បាប់របស់អង្គការពាណិជ្ជកម្មពិភពលោក៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណូមីស ចេញផ្សាយថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០២២។*

## អាមេរិក ដាក់បញ្ចូលគេហទំព័រលក់ទំនិញអនឡាញ Alibaba និង Tencent ក្នុងបញ្ជីខ្មៅ



*ដោយ freshnewsasia*

ការិយាល័យតំណាងពាណិជ្ជកម្មសហរដ្ឋអាមេរិក បានឱ្យដឹងថា គេហទំព័រលក់ទំនិញអនឡាញ E-commerce ដែលដំណើរការដោយក្រុមហ៊ុន Tencent និង Alibaba របស់ចិន ត្រូវបានបញ្ចូលទៅក្នុងបញ្ជីខ្មៅរបស់រដ្ឋាភិបាលអាមេរិក ដោយចោទប្រកាន់ថា ការលក់ផលិតផលក្លែងក្លាយ និងទាក់ទងទៅនឹងការលួចចម្លងកម្មសិទ្ធបញ្ញា។

ប្រទេសចិនបានប្រតិកម្មនឹងការសម្រេចចិត្តរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិក ក្នុងការបញ្ចូលគេហទំព័រលក់ទំនិញអនឡាញនៅក្នុង «**បញ្ជីខ្មៅ**» ដោយហៅសកម្មភាពនេះថា «**គ្មានទំនួលខុសត្រូវ**»។ ប្រទេសចិនបានជម្រុញឱ្យសហរដ្ឋអាមេរិក «ឆ្លុះបញ្ចាំងពីគោលបំណងនៃការខិតខំប្រឹងប្រែង និងវឌ្ឍនភាពដែលធ្វើឡើងដោយប្រទេសចិន» និងធ្វើការវាយតម្លៃដោយយុត្តិធម៌ដើម្បីជៀសវាងផលប៉ះពាល់អវិជ្ជមានដែលមិនសមរម្យលើក្រុមហ៊ុនរបស់ពួកគេ។

ក្រុមហ៊ុន Alibaba បានលើកឡើងថា ខ្លួននឹងបន្តធ្វើការយ៉ាងជិតស្និត ជាមួយរដ្ឋាភិបាលសហរដ្ឋអាមេរិកដើម្បីដោះស្រាយបញ្ហា ក្នុងការកាពារកម្មសិទ្ធបញ្ញានេះនៅគ្រប់ platforms របស់ខ្លួន ខណៈដែរ Tencent បានធ្វើការបដិសេធមិនយល់ស្រប ជាមួយនឹងការសម្រេចរបស់រដ្ឋាភិបាលសហរដ្ឋអាមេរិកឡើយ។

គួរជម្រាបដែរថា សហរដ្ឋអាមេរិក និងចិនបានជាប់ពាក់ព័ន្ធនឹងភាពតានតឹងផ្នែកពាណិជ្ជកម្មនេះអស់ជាច្រើនឆ្នាំមកហើយជុំវិញបញ្ហា ដូចជា ពន្ធគយ បច្ចេកវិទ្យា និងកម្មសិទ្ធិបញ្ញាជាដើម៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព ៖ freshnews ចេញផ្សាយថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២២។*

## គោលនយោបាយគាំទ្ររបស់ចិនសម្រាប់និស្សិតបញ្ចប់ការសិក្សាជាង១០លាននាក់នៅឆ្នាំ២០២២នេះ



*ដោយ ខេមបូណូមីស*

*តើរដ្ឋាភិបាលចិន មានគោលនយោបាយគាំទ្រអ្វីខ្លះសម្រាប់និស្សិតបញ្ចប់ការសិក្សានៅឆ្នាំ២០២២?*

ទីផ្សារការងាររបស់ចិន គឺជាអាទិភាពកំពូលសម្រាប់ទីក្រុងប៉េកាំង។ បញ្ហានេះ កើតឡើងចំពេលដែលចិនមានបញ្ហាប្រឈមផ្នែកសេដ្ឋកិច្ច រួមទាំង ការផ្ទុះឡើងនៃមេរោគឆ្លងជាបន្តបន្ទាប់ ដែលបន្តឱ្យមានការថ្លឹងថ្លែងលើការប្រើប្រាស់ ការធ្លាក់ចុះនៃទីផ្សារអចលនទ្រព្យ កង្វះខាតការផ្គត់ផ្គង់ដែលបានជំរុញឱ្យតម្លៃវត្ថុធាតុដើមកើនឡើង និងភាពតានតឹងក្នុងកត្តាភូមិសាស្ត្រនយោបាយជាដើម។ សហគ្រាសធុនតូច និងមធ្យម (SMEs) ដែលជាប្រភពការងារសំខាន់របស់ចិន បាននឹងកំពុងទទួលរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយជំងឺរាតត្បាត។ ជាក់ស្តែង អាជីវកម្មខ្នាតតូចបំផុតរបស់ចិន ប្រហែលជាង ៤ លាន បានបិទទ្វារអស់រយៈពេល១១ខែ កាលឆ្នាំមុន។ ក្នុងរយៈពេលប៉ុន្មានឆ្នាំថ្មីៗនេះ និស្សិតបញ្ចប់ការសិក្សានៅមហាវិទ្យាល័យមានចំនួនច្រើន ហើយមានខ្លះជាសហគ្រិន ប៉ុន្តែពួកគេមានការលំបាកក្នុងការទទួលបានហិរញ្ញប្បទាន កង្វះបទពិសោធន៍ និងសេវាកម្មក្នុងចំណោមបញ្ហាផ្សេងទៀតផងដែរ។

រដ្ឋាភិបាលចិន នឹងផ្តល់ជំនួយពិសេសដល់សហគ្រិនវ័យក្មេង ដោយសារអាជីវកម្មថ្មីនឹងអាចបង្កើតការងារបានច្រើន។ នៅក្នុងគោលនយោបាយអនុគ្រោះរបស់រដ្ឋាភិបាលចិន សម្រាប់និស្សិតទើបបញ្ចប់ការសិក្សា រួមមានការផ្តល់ទុនពីរដ្ឋសម្រាប់អាជីវកម្មបង្កើតថ្មី, ការផ្តល់កម្ចីពិសេស និងអត្រាការប្រាក់ទាប, កាត់បន្ថយការចំណាយ និងពន្ធ, ព្រមទាំងផ្តល់លទ្ធភាពសម្រាប់និស្សិតមហាវិទ្យាល័យក្នុងការរក្សាក្រេឌីតសាលា ខណៈដែលពួកគេបានឈប់សម្រាកជាច្រើនឆ្នាំ ដើម្បីចាប់ផ្តើមអាជីវកម្មជាដើម។ រដ្ឋាភិបាល បានប្រកាសពីការលើកទឹកចិត្តដល់អាជីវកម្មខ្នាតតូចណា ដែលផ្តល់ការងារដល់និស្សិតទើបបញ្ចប់ការសិក្សា តាមរយៈសិទ្ធិទទួលបានអត្ថប្រយោជន៍ និងប្រាក់កម្ចីជាមួយនឹងការកាត់បន្ថយការប្រាក់ជាដើម។ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណូមីស ចេញផ្សាយថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០២២។*

## ការបិទព្រំដែនម៉ុងហ្គោលី-ចិន ធ្វើឱ្យទំនិញឡើងថ្លៃ




*ដោយ khmer-posts*

នៅពេលដែលប្រទេសចិនបានបិទព្រំដែនរបស់ខ្លួន ដើម្បីព្យាយាមកម្រិតការគំរាមកំហែងនៃការរីករាលដាលនៃជំងឺរាតត្បាតកូវីដ-១៩ ទីផ្សារម៉ុងហ្គោលី បានចាប់ផ្តើមកើតមានអតិផរណា ដោយសារការពឹងផ្អែកលើផលិតផលនាំចូលពីប្រទេសចិន។ ប្រជាពលរដ្ឋមួយចំនួនបានត្អូញត្អែរថា ទំនិញប្រើប្រាស់ក្នុងផ្ទះ បន្លែ និងរបស់របរផ្សេងទៀតបានកើនឡើងបីដង ដែលបានប៉ះពាល់ដល់ជីវភាពរបស់ពួកគេ។ ស្រោមដៃពាក់ធ្វើការធ្លាប់តែតម្លៃ

៥០០តូហ្គ្រាក(ម៉ុងហ្គោលី) ឥឡូវនេះ មានតម្លៃដល់ទៅ ១៥០០តូហ្គ្រាក(០,៥២៤ដុល្លារ)។ ថង់សំរាម និងថង់ប្លាស្ទិចធ្លាប់មានតម្លៃពី ៤ ០០០-៥ ០០០តូហ្គ្រាក ប៉ុន្តែឥឡូវ ត្រូវចំណាយរហូតដល់ទៅ ១០ ០០០ តូហ្គ្រាក (ប្រហែល ៣,៤៩២ដុល្លារ)។ អ្នកលក់ម្នាក់បានប្រាប់ថា ការបិទព្រំដែននេះ បានរារាំងពួកគេមិនឱ្យទទួលបានទំនិញដែលពួកគេបញ្ជាទិញពីទីក្រុងប៉េកាំង ចាប់តាំងពីខែកញ្ញាមក ដូច្នេះហើយបានធ្វើឱ្យទំនិញទាំងអស់ "ក្លាយជាខ្វះខាត" ។

ការសម្រេចចិត្តរបស់ប្រទេសចិនលើការបិទព្រំដែនរបស់ខ្លួនជាមួយម៉ុងហ្គោលីមុនព្រឹត្តិការណ៍កីឡាអូឡាំ-ពិករដូវរងារ នៅទីក្រុងប៉េកាំង បានជះឥទ្ធិពលយ៉ាងខ្លាំងដល់ប្រទេសម៉ុងហ្គោលី ដោយតម្លៃទំនិញបានកើនឡើងយ៉ាងខ្លាំង៕ *ដោយ ម៉ែន ខែមរៈ*

*ប្រភព៖khmer-posts ចេញផ្សាយថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២២។*

## អឺរ៉ុបព្រមាន រុស្ស៊ីអាចនឹងបាត់បង់ការទទួលបានទីផ្សារហិរញ្ញវត្ថុ និងទំនិញសំខាន់ បើឈ្លានពានអ៊ុយក្រែន



*ដោយ ខេមបូណូមីស*

ប្រធានគណៈកម្មការអឺរ៉ុប បានបញ្ជាក់ច្បាស់ៗថា ប្រសិនបើរុស្ស៊ីឈ្លានពានអ៊ុយក្រែន នោះរុស្ស៊ីនឹងត្រូវកាត់ផ្តាច់ពីទីផ្សារហិរញ្ញវត្ថុអន្តរជាតិ និងក៏មិនអនុញ្ញាតឱ្យទទួលបាននូវមុខទំនិញសំខាន់ៗ ដែលផលិតពីលោកខាងលិចនោះទេ ដែលទំនិញទាំងនោះរុស្ស៊ីត្រូវការចាំបាច់ពីអឺរ៉ុបដើម្បីធ្វើទំនើបកម្ម និងធ្វើពិពិធកម្មសេដ្ឋកិច្ចរុស្ស៊ី។ លោកខាងលិច ជាកន្លែងផលិតផលិតផលសំខាន់ៗទាំងនោះ និងលេចធ្លោជាងគេនៅទូទាំងសកល។ ដូចនេះ ប្រសិនបើទំនិញទាំងនោះ ត្រូវបានបិទមិនឱ្យនាំចេញទៅរុស្ស៊ី នោះរុស្ស៊ីនឹងមិនមានទីផ្សារនាំចូលជំនួសនោះឡើយ។ ការដាក់ទណ្ឌកម្មនេះ នឹងធ្វើឡើង លុះត្រាតែរុស្ស៊ីឈ្លានពានអ៊ុយក្រែនតែប៉ុណ្ណោះ។ ដូចដែលបានដឹងហើយថា រុស្ស៊ីបានពឹងផ្អែកលើការនាំចេញឥន្ធនៈហ្វូស៊ីល ដែលឥន្ធនៈនេះ រុស្ស៊ីមានទំហំពីរភាគបីនៃការនាំចេញរបស់ខ្លួន ហើយពាក់កណ្ដាលនៃថវិការបស់រុស្ស៊ីបានមកពីការនាំចេញប្រេងឥន្ធនៈ។ ដូចនេះ ការពឹងផ្អែកខ្លាំងរបស់រុស្ស៊ីលើការនាំចេញប្រេងឥន្ធនៈនេះ អាចចាត់ទុកថាភាពទន់ខ្សោយរបស់រុស្ស៊ី ហើយក្នុងករណីរុស្ស៊ីត្រូវការធ្វើទំនើបកម្ម វាច្បាស់ណាស់ថា នឹងមិនអាចទៅរួចនោះឡើយ ប្រសិនបើការដាក់ទណ្ឌកម្មបន្ថែមទៀតពីលោកខាងលិចត្រូវបានធ្វើឡើងមែននោះ។

វិបត្តិរុស្ស៊ី-អ៊ុយក្រែននេះ គឺរុស្ស៊ីធ្វើឡើងដើម្បីទាមទារការធានាថា អ៊ុយក្រែននឹងមិនត្រូវបានអនុញ្ញាតឱ្យចូលរួមជាមួយសម្ព័ន្ធមិត្តណាតូ ខណៈដែលរុស្ស៊ីបារម្ភថា ប្រសិនបើអ៊ុយក្រែនចូលជាសមាជិកណាតូ នោះវានឹងប៉ះពាល់ដល់សន្តិសុខរយៈពេលវែងរបស់រុស្ស៊ី៕

*ដោយ ម៉ែន ខែមរៈ*

*ប្រភព៖ខេមបូណូមីស ចេញផ្សាយថ្ងៃទី២២ ខែកុម្ភៈ ឆ្នាំ២០២២។*

## JPMorgan រំពឹងថា ធនាគារសហព័ន្ធអាមេរិក នឹងបន្តតម្លើងការប្រាក់ ដើម្បីដោះស្រាយបញ្ហាអតិផរណា




*ប្រភព៖ FOXBusiness ២០២២*

ក្រុមអ្នកសេដ្ឋកិច្ចរបស់ក្រុមហ៊ុន JPMorgan Chase បានព្យាករថា ធនាគារសហព័ន្ធសហរដ្ឋអាមេរិក នឹងបន្តតម្លើងការប្រាក់ចំនួន ២៥ពិន្ទុគោល(០,២៥%) នៅក្នុងកិច្ចប្រជុំចំនួន ៩លើកទៀត ដើម្បីដោះស្រាយបញ្ហាអតិផរណាដែលមានសភាពធ្ងន់ធ្ងរជាងការរំពឹងទុក។ ថ្វីបើមិនមានបញ្ជាក់ពីពេលវេលាជាក់លាក់នៃការបញ្ឈប់ការតម្លើងការប្រាក់ក៏ដោយ ប៉ុន្តែបានផ្តល់ជាតម្រុយ នឹងធ្វើឡើងក្នុងកិច្ចប្រជុំនៅខែមីនា ឆ្នាំ២០២៣។

គួរបញ្ជាក់ថា សន្ទស្សន៍តម្លៃទំនិញអ្នកប្រើប្រាស់ ក្នុងខែមករា ឆ្នាំ២០២២ បានកើនឡើង ៧,៥% ធៀបនឹងខែមករា ឆ្នាំមុន ដែលនេះឆ្លុះបញ្ចាំងពីកំណើនលឿនខ្លាំងបំផុត ចាប់តាំងពីខែកុម្ភៈ ឆ្នាំ១៩៨២មក ដែលពេលនោះ អតិផរណា មានអត្រា ៧,៦%។ ដោយឡែក បើធៀបនឹងអតិផរណាខែមុន ឃើញមានការកើនឡើង ០,៦%។

ទន្ទឹមនេះដែរ អ្នកធ្វើគោលនយោបាយមួយចំនួន បានលើកឡើងថា ស្ថានភាពសេដ្ឋកិច្ចបច្ចុប្បន្ន នឹងអាចជួយសម្រួលដល់ការធ្វើប្រក្រតីភាពគោលនយោបាយបានលឿនជាងមុន បើធៀបនឹងឆ្នាំ២០១៥ ក៏ប៉ុន្តែ ចក្ខុវិស័យនេះ ផ្អែកលើវឌ្ឍនភាពក្នុងវិស័យហិរញ្ញវត្ថុ៕

*ដោយ ជា សិរីរតន៍*

*ប្រភព៖ FOXBusiness ចេញផ្សាយ ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២២*

## សេដ្ឋកិច្ចតំបន់ចាយប្រាក់អឺរ៉ូ បានងើបឡើង ទោះបីជាថ្លៃហក់ឡើងខ្ពស់



*ប្រភព៖ RTE ២០២២*

យោងតាមការស្ទង់មតិមួយ បានបង្ហាញថា ត្បិតតែតម្លៃទំនិញសម្រាប់អ្នកប្រើប្រាស់នៅតំបន់ចាយប្រាក់អឺរ៉ូ នៅខែកុម្ភៈនេះ បានកើនឡើងខ្ពស់ ប៉ុន្តែសេដ្ឋកិច្ចតំបន់នេះ បានបង្ហាញពីការងើបឡើងវិញយ៉ាងរហ័ស ដោយសារតែការបន្ធូរបន្ថយគោលនយោបាយរឹតត្បិត ដើម្បីជួយជំរុញដល់ឧស្សាហកម្មសេវាកម្ម។ ដោយឡែក វីរុសកូវីដ-១៩បំប្លែងថ្មី ដែលបានរីករាលដាលនៅទូទាំងអឺរ៉ុប បានធ្វើឱ្យរដ្ឋាភិបាលអឺរ៉ុបមួយចំនួន សម្រេចដាក់វិធានការទប់ស្កាត់ឡើងវិញ។

គួរបញ្ជាក់ថា សន្ទស្សន៍ Flash Composite Purchasing Managers របស់ IHS Markit ដែលត្រូវបានប្រើប្រាស់ដើម្បីពិនិត្យមើលលើសុខុមាលសេដ្ឋកិច្ចជារួម មានការកើនឡើង ដោយនៅក្នុងខែកុម្ភៈ មានពិន្ទុសរុប ៥៥,៨ ខណៈដែលមករា មានពិន្ទុ ៥២,៣ ហើយវាខ្ពស់ជាងការធ្វើស្ទង់មតិរបស់ Reuters ដែលមានពិន្ទុជាមធ្យម ៥២,៧។

លោក Chris Williamson ប្រធានសេដ្ឋកិច្ចផ្នែកធុរកិច្ច របស់ IHS Markit បាននិយាយថា ការងើបឡើងវិញនៃសេដ្ឋកិច្ចតំបន់នេះ បង្កពីការងើបឡើងនៃតម្រូវការជាថ្មីរបស់អ្នកប្រើប្រាស់ ក្នុងវិស័យសេវាកម្មជាច្រើន រួមមាន ដំណើរកំសាន្ត, ទេសចរណ៍ និងការកំសាន្ត។ លោកក៏បានបន្តទៀតថា ស្របពេលដែលតម្រូវការ មានទំហំខ្ពស់ជាងការផ្គត់ផ្គង់ រួមផ្សំជាមួយនឹង ការហក់ឡើងខ្ពស់នៃតម្លៃថាមពល និងថ្លៃឈ្នួលពលកម្ម បានដាក់សម្ពាធដល់អតិផរណា។ ជាក់ស្តែង អតិផរណានៅខែមករា បានកើនឡើងដល់កំណត់ត្រាខ្ពស់បំផុត ដែលបច្ចុប្បន្ន ធនាគារកណ្តាលសហគមន៍អឺរ៉ុប កំពុងស្ថិតក្រោមសម្ពាធ ក្នុងការរឹតបន្តឹងគោលនយោបាយរូបិយវត្ថុ៕ *ដោយ ជា សិរីតេន៍*

*ប្រភព៖ RTE ចេញផ្សាយ ថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២២*

## ទិន្នន័យស្រាវជ្រាវសម្រាប់សប្តាហ៍បន្ទាប់

ថ្ងៃចន្ទ ទី២៨ ខែកុម្ភៈ ឆ្នាំ២០២២

- ប្រទេសទួរគី បានប្រកាសឱនភាពពាណិជ្ជកម្ម ចំនួន 6.79 ពាន់លានដុល្លារក្នុងខែធ្នូ ឆ្នាំ 2021
- សន្ទស្សន៍តម្លៃទំនិញប្រើប្រាស់នៅក្នុងប្រទេសអេស្ប៉ាញបានធ្លាក់ចុះ 0.40%ក្នុងខែមករា ឆ្នាំ 2022 ធៀបនឹងខែមុន

ថ្ងៃអង្គារ ទី០១ ខែមីនា ឆ្នាំ២០២២

- ប្រទេសកូរ៉េខាងត្បូងបានប្រកាសឱនភាពពាណិជ្ជកម្មកម្រិតខ្ពស់បំផុត ក្នុងខែមករា ឆ្នាំ 2022
- ការមកដល់របស់ភ្ញៀវទេសចរបរទេសនៅក្នុងប្រទេសឥណ្ឌូនេស៊ីបានធ្លាក់ចុះ 0.28% ក្នុងខែធ្នូ ឆ្នាំ 2021

ថ្ងៃពុធ ទី០២ ខែមីនា ឆ្នាំ២០២២

- ប្រទេសប្រេស៊ីលបានកត់ត្រាឱនភាពពាណិជ្ជកម្មចំនួន 0.176 ពាន់លានដុល្លារក្នុងខែមករា ឆ្នាំ 2022
- អត្រានីកម្មភាព ក្នុងប្រទេសអាឡឺម៉ង់ឈរនៅ 3.2%ក្នុងខែធ្នូ ឆ្នាំ 2021

ថ្ងៃព្រហស្បតិ៍ ទី០៣ ខែមីនា ឆ្នាំ២០២២

- អតិរេកពាណិជ្ជកម្មរបស់ប្រទេសអូស្ត្រាលីបានធ្លាក់ចុះមកនៅត្រឹម 8.36 ពាន់លាន AUD ក្នុងខែធ្នូ ឆ្នាំ 2021
- ចំនួនអ្នកទេសចរបរទេសមកដល់ប្រទេសអេស្បាញបានកើនឡើង 355% ក្នុងខែធ្នូ ឆ្នាំ 2021

ថ្ងៃសុក្រ ទី០៤ ខែមីនា ឆ្នាំ២០២២

- អតិរេកពាណិជ្ជកម្មអាឡឺម៉ង់បានធ្លាក់ចុះមកត្រឹម 7 ពាន់លានអឺរ៉ូក្នុងខែធ្នូ ឆ្នាំ 2021 ពី 15.1 ពាន់លានអឺរ៉ូកាលពីឆ្នាំមុន
- សមតុល្យសាច់ប្រាក់រតនាគារនៅក្នុងប្រទេសទួរគីបាន នៅក្នុងខែធ្នូឆ្នាំ 2021៕